**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2011, 11:00
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬអង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហឧក្រិដ្ឋកម្មរួម ទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត**

---

**ដាក់ដោយ៖**

សហព្រះរាជអាជ្ញា៖
ជា លាង
Andrew CAYLEY

**ផ្ញើជូន៖**

ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖
ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន៖**

ជនត្រូវចោទ៖
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Elisabeth SIMMONEAU-FORT

**សហមេធាវីការពារក្តី៖**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
ស សូវាន
Jacques VERGÈS

# I. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន៩២ និង៩៨(២) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាដាក់ជូនសារណានេះ ដើម្បីគាំទ្រសំណើរបស់ខ្លួន សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកទម្រង់ទូលំទូលាយនៃសហកម្មឧក្រិដ្ឋកម្មរួមទី៣ (“សហកម្មឧក្រិដ្ឋកម្មរួម III”) ថាជាទម្រង់នៃការទទួលខុសត្រូវដែលជាជម្រើសមួយទៀត។ សំណើសុំនេះអាចត្រូវបាននិយាយម៉្យាងទៀតថា ជាសំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកំណត់បទចោទនៃអង្គហេតុទាំងឡាយដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញ នៅពេលចេញសាលក្រមថាជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងអនុលោមតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III (ប្រសើរជាងតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I ឬ II) ទៅតាមករណីសមស្រប។

២. សហព្រះរាជអាជ្ញាបានប្រកាន់ខ្ជាប់ខ្ជួននូវគោលជំហរដដែលថា ទម្រង់ទីមួយនៃសហឧក្រិដ្ឋកម្មរួម (“សហកម្មឧក្រិដ្ឋកម្មរួម I”) ឆ្លុះបញ្ចាំងល្អបំផុត អំពីលក្ខណៈនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ ដោយផ្អែកលើភ័ស្តុតាងក្នុងសំណុំរឿង រួមទាំងភ័ស្តុតាងដែលបានយោងនៅក្នុងដីកាសន្និដ្ឋានស្ថាពរ និងដីកាដំណោះស្រាយផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយគិតដល់ក្របខណ្ឌនីតិវិធីរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញានឹងមិនមានឱកាសពិនិត្យទៅលើសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានកោះអញ្ជើញមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ និងត្រូវពឹងផ្អែកលើការវាយតម្លៃចាស់លើសក្ខីកម្មរបស់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី។ ដូចនេះសហព្រះ-រាជអាជ្ញា ទទួលស្គាល់ថា គឺអាចមានលទ្ធភាពថា ចំនួនដែលមានកំណត់ដ៏តិចតួចនៃព្រឹត្តិការណ៍ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ អាចមិនស្ថិតនៅក្នុងវិសាលភាពនៃផែនការឧក្រិដ្ឋរួមដូចដែលបានគិតឃើញកាលពីដំបូងនោះឡើយ ទោះបីជាចំណុចនេះអាចកើតឡើងតិចតួចក្ដី។

៣. ប្រសិនបើភ័ស្តុតាងត្រូវតែបង្ហាញឱ្យឃើញថា អំពើឧក្រិដ្ឋមួយចំនួនដែលបានធ្វើឡើងដោយសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួម មិនស្ថិតនៅក្នុងផែនការឧក្រិដ្ឋរួមនោះក្ដី ក៏សហព្រះរាជអាជ្ញាត្រូវតែជូនជាសេចក្ដីសន្និដ្ឋានថា ទោះជាយ៉ាងណាក៏ដោយ ជនជាប់ចោទត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើទាំងនេះ ពីព្រោះវាជាផលវិបាកជាធម្មជាតិ និងដែលអាចប្រមើលមើលឃើញច្បាស់ជាមុនអំពីផែនការឧក្រិដ្ឋ និងជនជាប់ចោទម្នាក់ៗនៅតែសុខចិត្តទទួលយកហានិភ័យនៃឧក្រិដ្ឋកម្មនានា

ដែលនឹងត្រូវប្រព្រឹត្តឡើងដោយចេតនា ហើយបន្តចូលរួម និងរួមចំណែកយ៉ាងសំខាន់នៅក្នុងសហឧក្រិដ្ឋកម្មរួមនេះ។ ហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ជាទម្រង់នៃការទទួលខុសត្រូវដែលជាជម្រើសមួយទៀត។

៤. ដូចដែលបានពណ៌នាពិស្តារខាងក្រោម សហព្រះរាជអាជ្ញាជឿថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III គឺជាទម្រង់ នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅ អ.វ.ត.ក ដោយសារមូលហេតុដូចខាងក្រោមនេះ៖

(ក) មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក អនុញ្ញាតឱ្យមានការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ទូលំទូលាយនៃសហកម្មឧក្រិដ្ឋកម្មរួម (សហកម្មឧក្រិដ្ឋកម្មរួម III) នៅ អ.វ.ត.ក។

(ខ) ការទទួលខុសត្រូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

(គ) ការអនុវត្តការទទួលខុសត្រូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នៅ អ.វ.ត.ក គោរពតាមគោលការណ៍នីត្យានុកូលភាព រួមទាំងលក្ខខណ្ឌនៃការដឹងថាមានច្បាប់ចែង និងភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋចំពោះជនជាប់ចោទ។

(ឃ) ការទទួលខុសត្រូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ស៊ីសង្វាក់គ្នាជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ។

## II. ប្រវត្តិនីតិវិធី

៥. នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ មេធាវីការពារក្តី អៀង សារី បានដាក់ញត្តិមួយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតប្រកាសថា សហឧក្រិដ្ឋកម្មរួម ("សហកម្មឧក្រិដ្ឋកម្មរួម") អាចអនុវត្តបាននៅ អ.វ.ត.ក[១]។ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") បានចេញដីកាសម្រេចថា ទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម អាចអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលត្រូវបានជំនុំជម្រះទោស នៅចំពោះមុខ អ.វ.ត.ក ("ដីការបស់

[១] ញត្តិប្រឆាំងនឹងការអនុវត្តទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, ឯកសារ D97, ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨។

ក.ស.ច.ស សម្រេចអំពីសហកម្មឧក្រិដ្ឋកម្មរួម")[២]។ នៅខែមករា និងខែកុម្ភៈ ឆ្នាំ២០១០ ក្រុមមេធាវីការពារក្តី អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ម្នាក់ៗបានដាក់បណ្តឹងឧទ្ធរណ៍រៀងៗខ្លួនប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីសហកម្មឧក្រិដ្ឋកម្មរួម[៣]។

៦. នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីសហឧក្រិដ្ឋកម្មរួម ("សាលដីការបស់ អ.ប.ជ អំពីសហកម្មឧក្រិដ្ឋកម្មរួម")។ អ.ប.ជ បានបដិសេធបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីក្នុងវិសាលភាព ដែលបណ្តឹងឧទ្ធរណ៍ទាំងនោះបានអនុវត្តចំពោះទម្រង់ជាមូលដ្ឋាននៃសហកម្មឧក្រិដ្ឋកម្មរួម ("ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I") និងទម្រង់ជាលំដាប់លំដោយនៃ សហកម្មឧក្រិដ្ឋកម្មរួម ("ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម II")។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការពិចារណាអំពីទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III អ.ប.ជ បានបង្ហាញថា អ.ប.ជ បានពិចារណាឃើញថា ពុំមាន "ភ័ស្តុតាងគ្រប់គ្រាន់អំពីទស្សនៈច្បាប់ និងការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយ និងស៊ីគ្នាឡើយ នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២" [៤]។ ហេតុនេះ អ.ប.ជ បានសម្រេចថាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មិនអាចអនុវត្តជាទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខ អ.វ.ត.ក បានទេ[៥]។

៧. ការសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងដីកាដំណោះស្រាយ ដែលលើកឡើងយ៉ាងជាក់លាក់អំពីការអនុវត្តតែទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I និងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម II ប៉ុណ្ណោះ។

[២] ដីកាសម្រេចអំពីការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, ឯកសារ D97/13, ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩។

[៣] បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចស្តីពីការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម", ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១០, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, ឯកសារ D97/15/1, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម", សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, ឯកសារ D97/16/1, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១០។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានគេស្គាល់ថា ជាសហកម្មឧក្រិដ្ឋកម្មរួម" ឯកសារ D97/14/5, ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១០។

[៤] សាលដីកាសំរេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស (អ.ប.ជ ៣៨), ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ,កថាខណ្ឌ ៧៧ [ដែលចាប់ពីនេះ ទៅហៅថា "សាលដីការបស់ អ.ប.ជ ស្តីពី JCE"]។

[៥] សាលដីការបស់ អ.ប.ជ ស្តីពី JCE, កថាខណ្ឌ ៨៨។

## III. បញ្ហាបឋម

៨. ជាបញ្ហាបឋម សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា សំណើសុំរបស់ខ្លួនមានភាពត្រឹមត្រូវ អនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូង "ផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ដរាបណាមិនមានធាតុផ្សំណាថ្មីទៀតនៃបទចោទត្រូវបានដាក់បញ្ចូល" នៅក្នុងសាលក្រមរបស់ខ្លួន[៦]។ សំណើសុំប្រភេទនេះធ្លាប់មានពីមុនមក។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលយល់ព្រមតាមសំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងដែលសុំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការកំណត់បទចោទ នៃអង្គហេតុនានាដែលមាននៅចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីឲ្យស្របតាមទម្រង់នៃការទទួលខុសត្រូវថ្មី គឺទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ[៧]។ នៅក្នុងការវិភាគរបស់ខ្លួន អង្គបុរេជំនុំជម្រះបានបំភ្លឺថា ការកំហិតលើ "ការបញ្ចូលនូវធាតុផ្សំថ្មីនៃបទល្មើស" នៅក្នុងវិធាន ៩៨(២) ហាមឃាត់មិនឲ្យផ្លាស់ប្តូរការកំណត់បទចោទ ដែល "លើសពីអង្គហេតុទាំងឡាយដែលមានបង្ហាញនៅក្នុងឯកសារចោទប្រកាន់" ប៉ុន្តែមិនបានបដិសេធថាមិនឲ្យផ្លាស់ប្តូរទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់នោះទេ[៨]។

---

[៦] វិធានផ្ទៃក្នុងសម្រាប់ អវតក, វិសោធនកម្មលើកទី ៧, ថ្ងៃទី២៣ កុម្ភៈ ២០១១ [ដែលចាប់ពីនេះទៅហៅថា "វិធានសម្រាប់ អវតក"], វិធាន ៩៨(២) ។

[៧] ទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះសំណុំរឿង ០០១ មិនបានបញ្ចូលសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវក៏ដោយ អនុលោមតាមវិធាន ៩៨(២) អង្គជំនុំជម្រះសាលាដំបូង បានផ្លាស់ប្តូរការកំណត់បទចោទទៅលើអង្គហេតុនានា និងបានយល់ឃើញថា ជនជាប់ចោទមានការទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះបទឧក្រិដ្ឋផ្សេងៗ អាស្រ័យតាមការចូលរួមរបស់ខ្លួននៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមដែលមានលក្ខណៈជាប្រព័ន្ធ នៅមន្ទីរ ស-២១ ។ សាលក្រម, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E188, ថ្ងៃទី២៦ កក្កដា ២០១០ , [ដែលចាប់ពីនេះទៅហៅថា "សាលក្រមសំណុំរឿង ០០១"], កថាខណ្ឌទី ៤៩៦, ៥១៦ ។

[៨] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌ ៤៩៣, ៤៩៤។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ បានយល់ឃើញថា ឃ្លាដែលថា "ពុំមានធាតុផ្សំថ្មី" គឺជាការនិយាយជាដដែលឡើងវិញអំពី "ការបង្ហាញភស្តុតាងយ៉ាងច្បាស់អំពីមានការកំរិត [] ដែលថា ការផ្លាស់ប្តូរការកំណត់បទចោទថ្មីឡើងវិញណាមួយ មិនត្រូវធ្វើឲ្យលើសពីអង្គហេតុទាំងឡាយដែលមានចែងនៅក្នុងឯកសារចោទប្រកាន់នោះទេ"។ ដូចគ្នានឹងកថាខណ្ឌទី ៤៩៤ ខាងលើ។ ថ្វីដ្បិតតែមានសំអាងហេតុច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងក្តី ក៏មេធាវីការពារក្តី អៀង សារី បានលើកឡើងថា ការដាក់កំហិតមិនឲ្យបន្ថែម "ធាតុផ្សំថ្មី" មិនគ្របដណ្តប់តែលើធាតុផ្សំផ្នែកអង្គហេតុប៉ុណ្ណោះទេ ថែមទាំង ធាតុផ្សំគតិយុត្តិផងដែរ។ *សូមមើល* សេចក្តីអង្កេតរបស់ អៀង សារី ចំពោះការជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីបញ្ហាច្បាប់ នានាដែលសហព្រះរាជអាជ្ញាមានបំណងចង់លើកឡើងនៅពេលសវនាការបឋម[sic] អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសមួយទៀត

៩. សហព្រះរាជអាជ្ញាទទួលស្គាល់ថា វិធីដែលការផ្លាស់ប្តូរការកំណត់បទចោទ បានធ្វើឡើងត្រូវតែគោរពទៅតាមសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ ដូចមានចែងនៅក្នុងវិធាន ៣៥ នៃច្បាប់ អវតក ពោលគឺថា ជនជាប់ចោទតោងបានតែ "ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសា ដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន" និង "មានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តី និងការប្រាស្រ័យទាក់ទងជាមួយមេធាវីតាមការជ្រើសរើសរបស់ខ្លួន"[៩]។ ច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលអនុវត្តបទដ្ឋានស្រដៀងគ្នានេះ[១០] បង្ហាញថា ការកំណត់បទចោទឡើងវិញ ត្រូវបានអនុញ្ញាត ដរាបណាជនជាប់ចោទបានទទួលព័ត៌មានអំពីលទ្ធភាព ដែលអាចមានការផ្លាស់ប្តូរការកំណត់បទចោទ ហេតុដូច្នេះហើយជនជាប់ចោទមានឱកាសរៀបចំខ្លួន រួមទាំងការធ្វើសារណាផ្ទាល់មាត់ និងការធ្វើសារណាជាលាយលក្ខណ៍អក្សរស្តីពីបញ្ហាពាក់ព័ន្ធនានាផងដែរ[១១]។

---

អវតក/អជសង, ឯកសារ E9/30/1, ចុះថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១១ [ដែលចាប់ពីនេះតទៅហៅថា "សេចក្តីអង្កេតរបស់ អៀង សារី"], កថាខណ្ឌ ១០។ គោលជំហរនេះមិនអាចការពារបានទេ។ វិធីដំណើរការក្នុងការផ្លាស់ប្តូរការកំណត់បទចោទ តាមលក្ខណៈ របស់វាផ្ទាល់មានការពាក់ព័ន្ធនឹងការផ្លាស់ប្តូរធាតុផ្សំគតិយុត្តិ។ ការបកស្រាយណាមួយផ្សេងទៀតនៃវិធាន ៩៨(២) នៃវិធានផ្ទៃក្នុង នឹងធ្វើ ឱ្យបទបញ្ញត្តិលើសតតប្រយោជន៍។

[៩] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ដោយមានរួមបញ្ចូលនូវវិសោធនកម្មផ្សេងៗ ដូចដែល បានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ តុលា ២០០៤ (នស/រកម/១០០៤/០០៦) [ដែលចាប់ពីនេះទៅហៅថា "ច្បាប់ អវតក"], មាត្រា ៣៥ ។

[១០] *សូមមើល* អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារលេខ១១ និង១៤ ត្រង់មាត្រា៦.៣។

[១១] *សូមមើល* ឧទាហរណ៍ ករណីរឿងក្តីរបស់ *Pelissier និង Sassi* ទល់នឹង *ប្រទេសបារាំង* , តុលាការសិទ្ធមនុស្សទ្វីបអឺរ៉ុប, សំណុំរឿងលេខ [GC] ២៥៤៤៤/៩៤, ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៩ , កថាខណ្ឌ ៤២ និង ៦២ (ដោយរកឃើញថា ការរំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅពេលមានការបន្ថែមបទចោទប្រកាន់មួយថ្មីស្តីពីការជួយនិងជម្រុញគឺជនជាប់ចោទមិនបានដឹងទេរហូតទាល់តែដល់ពេលចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ទើបដឹង និងនៅពេលដែលជនជាប់ចោទគ្មានឱកាសធ្វើសារណាជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ទៅលើបញ្ហាដែលពាក់ព័ន្ធនានា នៅពេលដែលសាលាឧទ្ធរណ៍កំពុងជជែកពិភាក្សាគ្នា)។ ករណីរឿងក្តីរបស់ *Sipavicius* ទល់នឹង *Lithuania* EctHR (សំណុំរឿងលេខ ៤៩០៩៤/៩៩), ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២, កថាខណ្ឌទី ២៦, ៣១ ដល់ ៣២ (ដោយរកឃើញថាគ្មានការរំលោភទៅលើសិទ្ធិ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទនោះទេ ទោះបីជាជនជាប់ចោទមិនបានដឹងរហូតទាល់តែដល់ពេលចេញសាលដីកា ដែលថាបទចោទប្រកាន់លើរូបគាត់ត្រូវបានកំណត់ជាថ្មីឡើងវិញក៏ដោយ ពីព្រោះជនជាប់ចោទបានមានឱកាសនៅក្នុងពេលដំណើរការសវនាការលើបណ្តឹងឧទ្ធរណ៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាអង្គច្បាប់ និងបញ្ហាអង្គហេតុនានារួចហើយ និងធ្វើឱ្យការការពារក្តីរបស់ខ្លួនបានជឿនលឿនទៅមុខ)។ ករណីរឿងក្តីរបស់ *I.H. and Others* ទល់នឹង *ប្រទេសអូទ្រីស* ECHR (សំណុំរឿងលេខ ៤២៧៨០/៩៨), ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦, កថាខណ្ឌទី ៣៤ (ដែលរកឃើញថា ការរំលោភលើសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌នៅពេលដែលជនជាប់ចោទមិនបានបញ្ជាក់ថា តុលាការជម្រះក្តីសាមញ្ញអាចនឹងឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានដែលខុសគ្នាពីរដ្ឋអាជ្ញា ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិនៃបទល្មើស និងដោយលើកឡើងថា "ដើម្បីឱ្យមានការអនុវត្តសិទ្ធិក្នុងការការពារក្តីបានប្រកបដោយប្រសិទ្ធភាព មេធាវីការពារក្តីត្រូវតែទទួលបានក្នុងដៃរបស់ខ្លួននូវព័ត៌មានលំអិតឱ្យបានពេញលេញ អំពីបទចោទប្រកាន់ដែលត្រូវបានធ្វើឡើង ដែលរួមទាំងការកំណត់បទចោទដែលតុលាការអាចអនុម័តយកនៅក្នុងបញ្ហានោះ។ ព័ត៌មាននេះត្រូវតែផ្តល់នៅឱ្យមុនសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសមួយទៀត

១០. សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទត្រូវបានជូនដំណឹងអំពីលទ្ធភាពដែលថាទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួមអាចត្រូវបានយកមកអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង។ ជនជាប់ចោទបានទទួលព័ត៌មានតាមរយៈសារណារបស់សហព្រះរាជអាជ្ញា។ ការបញ្ជាក់របស់សហព្រះរាជអាជ្ញាកាលពីមុនអំពីចេតនារបស់ខ្លួន ក្នុងការស្នើសុំឲ្យកំណត់បទចោទជាថ្មីឡើងវិញ[១២] និងប្រការដែលថា បញ្ហាស្តីពីភាពអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋកម្មរួម រួមទាំងសហកម្មឧក្រិដ្ឋកម្មរួម III ជាពិសេស ត្រូវបានជជែកតវ៉ាគ្នាយ៉ាងល្អិតល្អន់ នៅដំណាក់កាលមុនសវនាការជំនុំជម្រះ និងនៅក្នុងសំណុំរឿង ០០១ នៅ អ.វ.ត.ក។ ចំណែកឯលក្ខខណ្ឌដែលតម្រូវឲ្យមានការត្រៀមរៀបចំឲ្យបានគ្រប់គ្រាន់ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា បញ្ហានេះត្រូវបានលើកឡើងមុនពេលចាប់ផ្តើមសវនាការរួចហើយ ហើយដែលជនជាប់ចោទនឹងមានឱកាសបញ្ជាក់អំពីទស្សនៈរបស់ខ្លួនស្តីពីទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ដើម្បីឆ្លើយតបទៅនឹងសារណាពេលនេះ។

១១. ស្របតាមការលើកឡើងខាងលើ ការកំណត់បទចោទជាថ្មីឡើងវិញណាមួយដែលនឹងធ្វើឡើង នៅពេលសម្រេចសេចក្តី គួរតែឲ្យស្របទៅនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីចៀសវាងភាពមិនប្រាកដប្រជាដែលអាចកើតមានឡើង សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះសាលាដំបូងឲ្យសម្រេចអំពីភាពអាចអនុវត្តបាននៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នៅមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការ ឬមួយក៏ឲ្យធ្វើការបញ្ជាក់ជាផ្លូវការថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីធ្វើការពិចារណាដោយយកចិត្តទុកដាក់។

---

ពេលសវនាការ នៅក្នុងលិខិតស្នើចោទប្រកាន់ជាផ្លូវការ ឬយ៉ាងហោចណាស់នៅក្នុងពេលដំណើរការសវនាការតាមវិធីផ្សេងទៀត ដូចជាការបន្ថែមបទចោទប្រកាន់ជាផ្លូវការ ឬដោយប្រយោល")។

[១២] ថ្មីៗនេះ មេធាវីការពារក្តី អៀង សារី បានលើកឡើងតវ៉ាថា សំណើសុំកំណត់បទចោទជាថ្មីឡើងវិញរបស់ សហព្រះរាជអាជ្ញា គឺជា "អញ្ញត្រកម្មបឋម" អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង ដោយសារវាបង្កើតបានទៅជាអញ្ញត្រកម្មអំពីយុត្តាធិការរបស់អវតក។ *សូមមើល* សេចក្តីសង្កេតរបស់ អៀង សារី, កថាខណ្ឌ ៦។ ចំណុចនេះ គឺមិនត្រឹមត្រូវទេ។ ទីមួយ សហព្រះរាជអាជ្ញា ពុំមាន "ការជំទាស់" ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់របស់ អ.វ.ត.ក ដែលបង្កើតបានទៅជាចំណុចពាក់ព័ន្ធនៃសេចក្តីយោង នោះទេ។ ទីពីរ បញ្ហាអំពីថាតើអង្គហេតុជាពិសេសណាមួយចំនួនត្រូវបានកំណត់បទចោទតាមវិធីដូចម្តេចនោះ គឺមិនមែនជាបញ្ហាផ្នែកយុត្តាធិការនោះទេ។ តាមការពិត អង្គជំនុំជម្រះសាលដំបូងមិនបានចាត់ទុកសំណើប្រភេទនេះថាជាអញ្ញត្រកម្មបឋមពីមុនអនុលោមតាមវិធាន៨៩ឡើយ។ *សូមមើល* សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ១៤, ៤៨៩ (ដែលគេអាចទាញចេញជាសេចក្តីសន្និដ្ឋានថា សំណើរបស់សហព្រះរាជអាជ្ញានៅក្នុងពេលសវនាការបឋមដែលសុំឲ្យយកមកអនុវត្តនូវសហកម្មឧក្រិដ្ឋកម្មរួម អនុលោមតាមវិធាន ៩៨(២) មិនត្រូវបានគេចាត់ទុកថាជាអញ្ញាត្រកម្មបឋមមួយ ជាបញ្ហាផ្នែកយុត្តាធិការនោះទេ ពីព្រោះអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "ពុំមានអញ្ញត្រកម្មទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក" ដែលត្រូវបានលើកឡើងនៅក្នុងពេលសវនាការបឋមនោះឡើយ)។

## IV. ឧត្ដិករណ៍

១២. ចំពោះទម្រង់នៃការទទួលខុសត្រូវដែលត្រូវអនុវត្តនៅ អ.វ.ត.ក ត្រូវតែបំពេញតាមលក្ខខណ្ឌទាំងបួនគឺ៖ (១) ត្រូវតែមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ដោយច្បាស់ៗ ឬដោយប្រយោល។ (២) ត្រូវតែមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលពាក់ព័ន្ធ។ (៣) ច្បាប់ដែលមានចែងអំពីទម្រង់នៃការទទួលខុសត្រូវនេះ តោងតែបើកឱ្យជនជាប់ចោទអាចមានសិទ្ធិគ្រប់គ្រាន់ក្នុងការពិនិត្យមើលបាន នៅក្នុងពេលពាក់ព័ន្ធ។ និង (៤) ជនជាប់ចោទត្រូវតែអាចប្រមើលដឹងថា គាត់អាចនឹងត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើរបស់គាត់[១៣]។ ដូចដែលបានរៀបរាប់លម្អិតខាងក្រោមនេះ សហកម្មឧក្រិដ្ឋកម្មរួម III បានបំពេញគ្រប់តាមលក្ខខណ្ឌនីមួយៗក្នុងចំណោមលក្ខខណ្ឌទាំងអស់នេះ ហេតុដូច្នេះហើយ គឺជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពនៅ អ.វ.ត.ក។

### ក. មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ចែងអំពីការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម III

១៣. មាត្រា ២៩ នៃច្បាប់ អ.វ.ត.ក មានចែងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលរបស់ "ជនជាប់ សង្ស័យណាម្នាក់ដែលបានរៀបចំគម្រោង ញុះញង់ បញ្ជា ជួយ និងជម្រុញ ឬប្រព្រឹត្ត" បទឧក្រិដ្ឋ ដែលតុលាការនេះអាចផ្ដន្ទាទោសបាន[១៤]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថា "សញ្ញាណនៃការប្រព្រឹត្តតាមរយៈការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម មាន ចែងនៅក្នុងមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក" [១៥]។ សហព្រះរាជអាជ្ញាលើកឡើងថា សំអាងហេតុ មុនរបស់អង្គជំនុំជម្រះសាលាដំបូង គឺត្រឹមត្រូវសម្រាប់មូលហេតុជាច្រើន។

១៤. ទីមួយ ការប្រើប្រាស់ពាក្យពេចន៍នៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ជាក់ស្ដែងស្ទើរតែដូចគ្នាបេះបិទទៅនឹងបទបញ្ញត្តិស្រដៀងគ្នានៅក្នុងច្បាប់លក្ខន្តិកៈសម្រាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់

---

[១៣] *សូមមើល* សាលដីកាសម្រេចរបស់ អ.ប.ជ ស្ដីពី JCE, កថាខណ្ឌ ៤៣។ ករណីរឿងក្ដីរបស់ *រដ្ឋអាជ្ញា* តទល់នឹង *Milutinović* សាលដីកាសម្រេចលើញត្តិរបស់ Dragoljub Ojdanic ដែលតវ៉ាជំទាស់អំពីយុត្តាធិការ - ការទទួលខុសត្រូវចំពោះសហកម្មឧក្រិដ្ឋកម្មរួម , សំណុំរឿង IT-99-37-AR72, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៣ [ដែលចាប់ពីនេះទៅហៅថា "សាលដីកាលើរឿងក្ដី *Milutinović*"], កថាខណ្ឌទី ២១។

[១៤] ច្បាប់ អវតក, មាត្រា ២៩ (សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត*) ។

[១៥] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌទី ៥១១ ។

អតីតប្រទេសយូហ្គោស្លាវី (“ICTY”) តុលាការឧក្រិដ្ឋកម្ម អន្តរជាតិសម្រាប់រ្វ៉ាន់ដា (“ICTR”) និង តុលាការពិសេសសម្រាប់សេរ៉ាឡេអូន (“SCSL”)[១៦]។ តុលាការទាំងអស់នេះ បានបកស្រាយពាក្យថា “បានប្រព្រឹត្ត” ថារួមទាំងការចូលរួមនៅក្នុងការយល់ដឹងអំពីការរៀបចំផែនការ ឬគោលបំណងរួម[១៧]។ សហព្រះរាជអាជ្ញាលើកឡើងថា វាជាការត្រឹមត្រូវសម្រាប់អង្គជំនុំជម្រះសាលាដំបូងទទួលការណែនាំនៅក្នុងការបកស្រាយមាត្រា ២៩ របស់អង្គជំនុំជម្រះសាលាដំបូង តាមរយៈការបកស្រាយបទបញ្ញត្តិស្រដៀងគ្នានៅតុលាការនានាដែលដំណើរការប្រហាក់ប្រហែលគ្នា។

១៥. ទីពីរ នៅពេលដែលច្បាប់ អ.វ.ត.ក ត្រូវបានអនុម័ត នៅឆ្នាំ ២០០១ អ្នកធ្វើសេចក្តីព្រាងច្បាប់នេះ បានដឹងអំពីសាលដីកាដែលទើបចាប់ផ្តើមអំពីសហកម្មឧក្រិដ្ឋកម្មរួម ពោលគឺសាលដីការបស់អង្គជំនុំជម្រះសាលា ឧទ្ធរណ៍របស់តុលាការ ICTY នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Tadić* ។ ជាពិសេស អ្នកធ្វើសេចក្តីព្រាងច្បាប់បានដឹងថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានយល់ឃើញថា សហកម្មឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ សហកម្មឧក្រិដ្ឋកម្មរួម III ត្រូវបានបូកបញ្ចូលនៅក្នុងមាត្រា ៧(១) នៃច្បាប់លក្ខន្តិកៈ របស់តុលាការ ICTY ស្តីពីមូលដ្ឋាននៃកម្មវត្ថុ

---

[១៦] ច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY, ICTR និង SCSL មានចំណុចខុស គ្នាពីរតូចៗពីច្បាប់ អ.វ.ត.ក ដែលក្នុងនោះ (១) តុលាការ ICTY, ICTR និង SCSL បញ្ចូលពាក្យ “ម៉្យាងទៀត” នៅពីមុខពាក្យថា ការជួយ និងជម្រុញ។ និង (២) ទម្រង់នៃ ការទទួលខុសត្រូវក្នុងការប្រព្រឹត្តត្រូវបានរៀបរាប់ជាបញ្ជីមុន ការជួយ និងការជម្រុញ។ ច្បាប់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី, ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្ម នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៩ [ដែលចាប់ពីនេះទៅហៅថា “ច្បាប់លក្ខន្តិកៈតុលាការ ICTY”], មាត្រា ៧(១) (ចែងអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលបុគ្គល ចំពោះជនទាំងឡាយណាដែល “បានរៀបចំផែនការ បានញុះញង់ បានប្រព្រឹត្ត ឬម៉្យាងទៀត បានជួយ និងជម្រុញ” ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនានាដែលអាចត្រូវផ្តន្ទាទោសដោយតុលាការនេះ)។ ច្បាប់លក្ខន្តិកៈរបស់ តុលាការ ICTR ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ វិសោធនកម្ម ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ [ដែលចាប់ពីនេះទៅហៅថា “លក្ខន្តិកៈតុលាការ ICTR”] មាត្រា ៦(១) (ចែងដូចគ្នា)។ ច្បាប់លក្ខន្តិកៈរបស់តុលាការ SCSL ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ [ដែលចាប់ពី នេះទៅហៅថា “លក្ខន្តិកៈតុលាការ SCSL”] មាត្រា ៦(១) (ចែងដូចគ្នា)។ ដោយហេតុថា ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលបានចែងនៅ ក្នុងបញ្ញត្តិទាំងនេះត្រូវបានពណ៌នាថាប្រើប្រាស់ពាក្យពេចន៍ “តែមួយដូចគ្នា ដូចនៅក្នុងបញ្ញត្តិរបស់ អវតក ដែរ នោះ គឺមិនមានហេតុផល ដែលត្រូវគិតថាការលុបចេញនូវពាក្យ “ម្យ៉ាងទៀត” និងការរៀបចំពាក្យពេចន៍ឡើងវិញបន្តិចបន្តួច ថាជាការដែលមានចេតនាចង់ធ្វើឲ្យបទប្បញ្ញត្តិ របស់ អ.វ.ត.ក មានអត្ថន័យខុសគ្នានោះឡើយ។

[១៧] *សូមមើល* ឧទាហរណ៍ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា តទល់នឹង Tadić,* សាលដីកា, សំណុំរឿងលេខ IT-94-1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ [ដែលចាប់ពីនេះទៅហៅថា “សាលដីកាលើបណ្តឹងឧទ្ធរណ៍រឿងក្តី *Tadić*”] កថាខណ្ឌទី ២៣០ ដល់ ២៣៤។ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា តទល់នឹង Ntakirutimana* ,សាលដីកា, សំណុំរឿងលេខ ICTR-96-10-A និង លេខ ICTR-96-17-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTR, ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៤, កថាខណ្ឌទី ៤៦១ ដល់ ៤៨៤។ ករណីរឿងក្តីរបស់ *រដ្ឋអាជ្ញា តទល់នឹង Brima, Kamara និង Kanue* (ករណីរឿងក្តីរបស់ AFRC) សេចក្តីសម្រេចលើញត្តិស្នើសុំឲ្យចេញសាលក្រមឲ្យលើកលែងទោស អនុលោមតាមវិធាន ៩៨ , សំណុំរឿងលេខ SCSL-04-16-T, ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌទី ៣០៨ ដល់ ៣២៦។

និងគោលបំណងនៃច្បាប់លក្ខន្តិកៈ លក្ខណៈនៃឧក្រិដ្ឋកម្មអន្តរជាតិ ការពិនិត្យឡើងវិញអំពីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ និងការសិក្សាប្រៀបធៀបអំពីការតាក់តែងច្បាប់របស់ប្រទេសជាច្រើន[១៨]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ប្រសិនបើអ្នកធ្វើសេចក្ដីព្រាងច្បាប់ អ.វ.ត.ក មានបំណងដកសហកម្មឧក្រិដ្ឋកម្មរួម ឬជាពិសេសទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ចេញនោះ អ្នកធ្វើសេចក្ដីព្រាងច្បាប់ទាំងនោះ នឹងត្រូវធ្វើសេចក្ដីព្រាងចំពោះមាត្រា២៩ ខុសពីប្រការដែលបានប្រើប្រាស់នៅក្នុងច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY[១៩]។

១៦. ទីបី ការបញ្ចូលការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងច្បាប់ អ.វ.ត.ក គឺគោរពតាមកម្មវត្ថុ និងគោលបំណងរបស់ច្បាប់ អ.វ.ត.ក។ មាត្រា ១ នៃច្បាប់ អ.វ.ត.ក ចែងថា "គោលបំណង"របស់ច្បាប់ គឺនាំយក"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋនានា ក្រោមរបបនោះមកធ្វើការជំនុំជម្រះទោស។ ដើម្បីទទួលស្គាល់អំណាចរបស់ អ.វ.ត.ក ក្នុងការផ្ដន្ទាទោស "មេដឹកនាំជាន់ខ្ពស់" និងអ្នកទាំងឡាយណាដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋនានា មានការវែកញែកថា តុលាការនេះអាចដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌទៅលើបុគ្គលនានាដែលបានបង្កើត និងអនុវត្តគោលនយោបាយឧក្រិដ្ឋទាំងឡាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺមិនដាក់ការទទួលខុសត្រូវតែទៅលើបុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋផ្នែករាងកាយ ដែលកើតចេញមកពីគោលនយោបាយទាំងអស់នោះឡើយ។ សហកម្មឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលសមស្របបំផុតទៅនឹងភារកិច្ចនេះ។

## ខ. ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម III
## ដែលមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩

១៧. ខណៈពេលអង្គជំនុំជម្រះសាលាដំបូងបានអះអាងកាលពីពេលមុន អំពីការបង្កើតទម្រង់សហកម្ម

[១៨] សាលដីកាលើបណ្ដឹងឧទ្ធរណ៍រឿងក្ដី *Tadić*, កថាខណ្ឌទី ១៨៩, ១៩១, ១៩៥ ដល់ ២២៦។

[១៩] សម្រាប់ការពិភាក្សាបន្ថែមលើចំណុចនេះ *សូមមើល* ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្ដីពី JCE , សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៣៥, ៣៨ និង ៣៩), ឯកសារលេខ D97/16/5 កថាខណ្ឌទី ៥៥ ដល់ ៥៦។

ឧក្រិដ្ឋកម្មរួម I និង II នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[២០] អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចអំពីបញ្ហាថាតើទម្រង់ សហកម្មឧក្រិដ្ឋកម្មរួម III ត្រូវបានបង្កើតឡើងស្រដៀងគ្នា នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលនោះ ឬយ៉ាងណាឡើយ[២១]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថាទម្រង់ទាំងអស់នៃសហកម្មឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ទូលំទូលាយរបស់វា ត្រូវបានបង្កើតឡើងនៅពេលនោះ។

១៨. ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ទម្រង់ទាំងបីរបស់សហកម្មឧក្រិដ្ឋកម្មរួម រួមបញ្ចូលដោយធាតុផ្សំ *នៃអំពើពិរុទ្ធ* ដូចខាងក្រោមនេះ៖ (១)ចាំបាច់ត្រូវមានមនុស្សច្រើន (២)ចាំបាច់ត្រូវមានអត្ថិភាពនៃផែនការរួម គំរោងរួម ឬគោលបំណងរួមដែលស្មើទៅនឹង ឬមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធ និង(៣) ការចូលរួម "ដ៏សំខាន់" របស់ជនជាប់ចោទនៅក្នុងការរៀបចំផែនការរួមពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋនានា ដូចមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធ[២២]។

១៩. ទោះបីជាយ៉ាងណាក៏ដោយ ទម្រង់ខុសគ្នាទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងធាតុផ្សំអត្តនោម័តរបស់វា។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I ទម្រង់ II តម្រូវឲ្យមានការបង្ហាញថា បទឧក្រិដ្ឋដែលបានគូសបញ្ជាក់ត្រូវបានគិតថា៖ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I តម្រូវឲ្យជនជាប់ចោទត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ និងសហចារីទាំងអស់ ត្រូវតែមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋនេះផងដែរ[២៣] ខណៈពេលដែលទម្រង់សហកម្មឧក្រិដ្ឋកម្មរួម II តម្រូវឲ្យជនជាប់ចោទត្រូវតែបានដឹងអំពីចរិតលក្ខណៈនៃប្រព័ន្ធ និងមានចេតនាជួយជ្រោមជ្រែងប្រព័ន្ធធ្វើបាបជារួមនេះ[២៤]។ ទោះបីជាយ៉ាងណាក៏ដោយ អនុលោមតាមទម្រង់ ជនជាប់ចោទមិនចាំបាច់ត្រូវតែមានចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់នោះទេ។ ប៉ុន្តែ ជនជាប់ចោទអាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនានាដែលជាផលវិបាកជាធម្មជាតិ និងជាផលវិបាកដែលគេអាចមើលឃើញយ៉ាងច្បាស់ជាមុននៃផែនការរួម ដែលជនជាប់ចោទបានលើកឡើងពីចេតនារួមគ្នា ដរាបណាជនជាប់ចោទ "បានដឹងពីបទ

[២០] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌទី ៥១២។

[២១] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌទី ៥១៣។

[២២] សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៥០៨។ *សូមមើលផងដែរ* រឿងក្តីរបស់ *រដ្ឋអាជ្ញា ទល់នឹង Brdjanin,* សាលដីកា , សំណុំរឿងលេខ IT-99-36-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY, ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧, កថាខណ្ឌទី ៤៣០។

[២៣] សាលក្រមសំណុំរឿង ០០១, កថាខណ្ឌទី ៥០៩។

[២៤] សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៥០៩។

ឧក្រិដ្ឋនៅខាងក្រៅផែនការរួមដែលជាផលវិបាកជាធម្មជាតិ និងអាចមើលឃើញយ៉ាងច្បាស់ជាមុននៃផែនការ និង[...] ស្ម័គ្រចិត្តទទួលយកហានិភ័យនៃបទឧក្រិដ្ឋ"[២៥]។

២០. សហព្រះរាជអាជ្ញាស្នើថា អង្គជំនុំជម្រះសាលាដំបូងគួរអនុវត្តតាមវិធីសាស្ត្ររបស់សាលាឧទ្ធរណ៍របស់តុលាការ ICTY នៅក្នុងរឿងក្តី Tadic នៅក្នុងសំអាងហេតុដែលថា សញ្ញាណនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម រួមទាំងទម្រង់ទូលំទូលាយរបស់វាមានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ អនុលោមតាមច្បាប់អន្តរជាតិនានាដែលត្រូវបានអនុម័តក្រោយសង្គ្រាមលោកលើកទីពីរ និងយុត្តិសាស្ត្រដែលពាក់ព័ន្ធ[២៦]។ ច្បាប់អន្តរជាតិដែលពាក់ព័ន្ធនានាដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានយកធ្វើជាសំអាង រួមបញ្ចូលនូវធម្មនុញ្ញទីក្រុងឡុងដ៍របស់តុលាការយោធាអន្តរជាតិ ("ធម្មនុញ្ញ IMT" និង "IMT" ដាច់ដោយឡែកពីគ្នា)[២៧]។ ច្បាប់គ្រប់គ្រងក្រុមប្រឹក្សាលេខ ១០ ("CCL១០")[២៨] និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា("ធម្មនុញ្ញចុងបូព៌ា")[២៩]។ ការបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់តុលាការ ICTY អាចយកមកអនុវត្តបានដោយស្មើភាពគ្នាចំពោះ អ.វ.ត.ក ពីព្រោះពុំមានការអភិវឌ្ឍសំខាន់ពាក់ព័ន្ធ នៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និងការបង្កើតតុលាការ ICTY នៅឆ្នាំ១៩៩៣ នោះទេ។

២១. លើសពីនេះទៀត ដូចដែលសហព្រះរាជអាជ្ញាបានអះអាងពីពេលមុនថា ធម្មនុញ្ញតុលាការអន្តរជាតិនាទីក្រុងនូរ៉ាំប៊ឺហ្គ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ និងយុត្តិសាស្ត្រដែលពាក់ព័ន្ធ រួមគ្នាបង្កើតបានជាអ្វីដែលអ្នកប្រាជ្ញច្បាប់អន្តរជាតិហៅថា "Grotian Moment"[៣០]។ ឱកាសបែបនេះ កើត

---

[២៥] សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៥០៩។

[២៦] គោលជំហររបស់តុលាការ ICTY ស្តីពី JCE ត្រូវបានអះអាងនៅក្នុងរឿងក្តីបន្តបន្ទាប់នៅតុលាការ ICTY និងនៅតុលាការ ICTR តុលាការ SCSL និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ("STL")។ សូមមើលខាងក្រោម កថាខណ្ឌទី ១៤, លេខយោងជើងទំព័រទី១៧។ សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ខំនៅក្នុងច្បាប់នានាជាធរមាន៖ អំពើភេរវកម្ម ការសមគំនិត មនុស្សឃាត ការប្រព្រឹត្តិបទឧក្រិដ្ឋ ការចោទប្រកាន់ត្រួតលើគ្នា, សំណុំរឿងលេខ STL-11-01/1 ; តុលាការពិសេសសម្រាប់ប្រទេសលីបង់, ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ [ដែលចាប់ពីនេះទៅហៅថា "សេចក្តីសម្រេចបន្ទាន់បង្ខំរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់"], កថាខណ្ឌទី ២៣៩ ដល់ ២៤៧។

[២៧] ធម្មនុញ្ញទីក្រុងឡុងដ៍របស់តុលាការយោធាអន្តរជាតិ, ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥, មាត្រា ៦ [ដែលចាប់ពីនេះទៅហៅថា "ធម្មនុញ្ញ IMT"]។

[២៨] ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ ១០ នៅក្នុងការផ្សាយជាផ្លូវការរបស់ក្រុមប្រឹក្សាត្រួតពិនិត្យសម្រាប់ប្រទេសអាល្លឺម៉ង់ (ឆ្នាំ ១៩៤៦) លេខ ៣ ទំព័រ ៥០ [ដែលចាប់ពីនេះទៅហៅថា "CCL 10"] ។

[២៩] ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦, មាត្រា ៥។

[៣០] *សូមមើល* សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាអំពី JCE, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨, កថាខណ្ឌទី ១១ ដល់ ២៥។

ឡើងនៅពេលមានការអភិវឌ្ឍន៍ផ្លាស់ប្តូរ ដែលក្នុងនោះ វិធាន និងទ្រឹស្តីថ្មីៗនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានកើតមានឡើងឆាប់រហ័ស និងមានការទទួលស្គាល់ខុសពីធម្មតា[៣១]។

២២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ទ្រឹស្តីមួយក្នុងចំណោមទ្រឹស្តីច្បាប់ទំនៀមទម្លាប់ដែលបានកើតឡើងដោយសារសង្គ្រាមលោកលើកទី២ គឺជាវិធានដែលបុគ្គលនានាចូលរួមនៅក្នុងផែនការឧក្រិដ្ឋកម្មរួមអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះអំពើនានា ដែលបានប្រព្រឹត្តឡើងដោយអ្នកផ្សេងទៀតនៅក្នុងការអនុវត្តផែនការនោះ។ វិធាននេះមាននៅក្នុងមាត្រា៦ នៃធម្មនុញ្ញតុលាការអន្តរជាតិទីក្រុងនូរ៉ំប៊ឺហ្គ ដែលបានចែងថា បុគ្គលនានា "ដែលបានចូលរួមនៅក្នុងការបង្កើត ឬអនុវត្តផែនការរួម ឬការសមគំនិតប្រព្រឹត្ត[បទឧក្រិដ្ឋណាមួយក្នុងចំណោមបទឧក្រិដ្ឋនានា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ]ត្រូវទទួលខុសត្រូវចំពោះរាល់អំពើទាំងអស់ ដែលបានប្រព្រឹត្តដោយជនណាក៏ដោយដែលអនុវត្តតាមផែនការនេះ"[៣២] និងនៅក្នុងមាត្រា II (២)(ឃ) ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដែលបានចែងថា បុគ្គលម្នាក់អាចត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយអនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ប្រសិនបើបុគ្គលនោះ "មានការទាក់ទងជាមួយនឹងផែនការ ឬសហកម្មឧក្រិដ្ឋកម្មរួមដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិផែនការសហកម្មឧក្រិដ្ឋកម្មរួមនោះ"[៣៣]។

២៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថែមទៀតថា ទស្សនាទាននៃការទទួលខុសត្រូវផែនការសហកម្មឧក្រិដ្ឋកម្មរួម ដែលមាននៅក្នុងច្បាប់អន្តរជាតិនានា ត្រូវបានប្រើប្រាស់នៅក្នុងច្បាប់យុត្តិសាស្ត្រអន្តរជាតិក្រោយសង្គ្រាមលោកលើកទី២ រួមបញ្ចូលនូវសញ្ញាណនៃអ្វីដែលត្រូវបានសំអាងថាជាការទទួលខុសត្រូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ដូចជា គំនិតដែលជនជាប់ចោទម្នាក់អាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋនានាដែលជនជាប់ចោទមិនចាំបាច់ត្រូវមានចេតនានោះទេ ប៉ុន្តែត្រូវតែជាផលវិបាកជាធម្មជាតិ និងអាចយល់ដឹងច្បាស់ជាមុនអំពីផែនការសហកម្មឧក្រិដ្ឋកម្មរួម ដែលជនជាប់ចោទ បានចូលរួមដោយចេតនា។ សេចក្តីសន្និដ្ឋាននេះសមហេតុផល បន្ទាប់ពីពិចារណាអំពីកម្មវត្ថុ និងគោលបំណងនៃធម្មនុញ្ញតុលាការអន្តរជាតិទីក្រុងនូរ៉ំប៊ឺហ្គ និងការជំនុំជម្រះទោស

---

[31] *សូមមើល ឧទាហរណ៍ដូចជា* នៅក្នុងករណីរឿក្តីរបស់ Leila Nadya Sadat "ការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ: ពីទីក្រុងឡាអេ ទៅទីក្រុងរ៉ូម និងត្រឡប់មកវិញម្តងទៀត" ៨ Mich. St. U. J. Int'l L. 97, 101 (ឆ្នាំ ១៩៩៩) (ដោយតវ៉ាថា សន្និសីទនៃទីក្រុងរ៉ូមដែលបង្កើតច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ បានបង្កើតនូវ "Grotian Moment" មួយ នៅក្នុងច្បាប់អន្តរជាតិ។

[៣២] ធម្មនុញ្ញ IMT, មាត្រា ៦។

[៣៣] CCL 10, មាត្រា II (២)(ឃ)។ *សូមមើលផងដែរ* ធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៤៦, មាត្រា ៥។

ក្រោយសង្គ្រាមលោកលើកទី២ ដូចជាការដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ជាលក្ខណៈបុគ្គលចំពោះសហកម្មឧក្រិដ្ឋកម្មរួមនានា។ អត្ថិភាពនៃគោលការណ៍នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរឿងក្តីដែលសម្រេចតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ យ៉ាងហោចណាស់ចំនួនពីររឿង[៣៤] ដែលត្រូវបានបរិយាយពិស្តារ ដូចខាងក្រោម៖

២៤. រឿងក្តីទីមួយ ដែលត្រូវបានជំនុំជម្រះទោសដោយតុលាការយោធាអង់គ្លេសសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋជនសង្គ្រាម ត្រូវបានគេស្គាល់ថាជា រឿងក្តី *Essen Lynching*[៣៥]។ នៅក្នុងរឿងក្តីនេះ មនុស្សចំនួន៧នាក់ត្រូវបានចោទប្រកាន់រួមគ្នាពីបទសម្លាប់មនុស្សដែលជាឧក្រិដ្ឋកម្មសង្គ្រាម ដែលផ្អែកលើការចោទប្រកាន់ថា ពួកគេមានការពាក់ព័ន្ធនៅក្នុងការសម្លាប់ឈ្លើយសឹកជនជាតិអង់គ្លេសចំនួន៣នាក់។ ជនជាប់ចោទពីរនាក់ក្នុងចំណោមជនជាប់ចោទទាំងអស់ គឺជាសមាជិកកងទ័ពអាល្លឺម៉ង់។ ជនជាប់ចោទដែលនៅសល់ផ្សេងទៀតគឺជាជនស៊ីវិល។ យោងតាមការចោទប្រកាន់ អំពើខុសច្បាប់របស់ជនជាប់ចោទបានកើតឡើងនៅក្នុងដំណាក់កាលចំនួនបី។ ទីមួយ ជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទនៅក្នុងរឿងក្តី ដែលជាអនុសេនីយ៍ឯកនៅក្នុងកងទ័ពអាល្លឺម៉ង់ បានណែនាំជនជាប់ចោទម្នាក់ទៀតដែលជាពលទោ ឲ្យនាំឈ្លើយសឹកជនជាតិអង់គ្លេសទាំងបីនាក់ ពីបន្ទាយទាហានដែលជាកន្លែងទុកពួកគេនៅទីនោះ ទៅកាន់អគារមួយទៀតដែលជាកន្លែងគេត្រូវសួរចម្លើយឈ្លើយសឹកទាំងបីនាក់នោះ កាត់តាមទីក្រុង Essen របស់អាល្លឺម៉ង់។ ការណែនាំរបស់អនុសេនីយ៍ឯក ត្រូវបានធ្វើឡើងនៅចំពោះមុខប្រជាជនស៊ីវិលមួយហ្វូង ហើយពលទោនោះត្រូវបានបញ្ជាមិនឲ្យ "ធ្វើអន្តរាគមន៍ទេ ទោះក្នុងករណីណាក៏ដោយ ប្រសិនបើហ្វូងប្រជាជនធ្វើបាប

---

[៣៤] តុលាការឧក្រិដ្ឋកម្មអន្តរជាតិជាញឹកញាប់ចាត់ទុក CCL 10 និងច្បាប់យុត្តិសាស្ត្រពាក់ព័ន្ធជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់ អន្តរជាតិ។ សូមមើល ឧទាហរណ៍ សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម (JCE) សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៣៨) ឯកសារ D97/15/9 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៥៧ (ដោយលើកឡើងថា CCL 10 គឺជាច្បាប់ ដែលបានបង្កើតឡើង "ឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងអន្តរជាតិដែលស្ថិតក្នុងចំណោមប្រទេសអំណាចធំៗស្តីពីច្បាប់ជាធរមានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងច្បាប់យុត្តិសាស្ត្ររបស់តុលាការយោធាដែលទាមទារនូវវិធានស្តីពីឧក្រិដ្ឋកម្មទាំងនេះ") (សេចក្តីបញ្ជាក់ បន្ថែម)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kupreskic* សាលក្រម IT-95-16-A អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤១ (ដែលបង្ហាញថា CCL 10 គឺជាច្បាប់មួយក្នុងចំណោមច្បាប់អន្តរជាតិនានា "ដែលដាក់នូវបទបញ្ញត្តិដែលប្រកាសពីច្បាប់ដែលមានស្រាប់ ឬដែលត្រូវបានក្លាយខ្លួនបន្តិចម្តងៗចូលទៅក្នុងច្បាប់ទំនៀមទម្លាប់ អន្តរជាតិ")។

[៣៥] សវនាការជំនុំជម្រះក្តីលើឈ្មោះ Erich Heyer និងអ្នកផ្សេងទៀតចំនួន ៦ នាក់, តុលាការយោធាអង់គ្លេសសម្រាប់ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម, នៅ Essen, ពីថ្ងៃទី ១៨ ដល់ ១៩ និងថ្ងៃទី ២១ ដល់ ២២ ខែធ្នូ ឆ្នាំ ១៩៤៥, UNWCC លេខ ១ (ឆ្នាំ ១៩៤៩) [ដែលចាប់ពីនេះទៅហៅថា "*ករណីរឿងក្តី Essen ស្តីពីការសម្លាប់ដោយគ្មានតុលាការជំនុំជម្រះ*"], ទំព័រ ៨៨។

អ្នកទោសទាំងនោះ"[៣៦]។ នៅក្នុងដំណាក់កាលទីពីរ អ្នកទោសត្រូវបានបណ្តើរដោយពលទាហានអាល្លឺម៉ង់ឲ្យដើរដង្ហែរកាត់តាមទីក្រុង ខណៈពេលហ្វូងមនុស្សដែលបានប្រមូលផ្តុំគ្នា ត្រូវបានអនុញ្ញាតឲ្យវាយឈ្លើយសឹកទាំងបីនាក់ជាមួយនឹងដំបង និងគប់ដុំថ្ម។ ជាចុងក្រោយ សមាជិកហ្វូងមនុស្សបានគ្រវែងឈ្លើយសឹកទាំងបីនាក់ទៅលើស្ពាន។ ឈ្លើយសឹកម្នាក់បានស្លាប់ពេលធ្លាក់ចុះមកវិញ នៅពេលដែលឈ្លើយសឹកពីរនាក់ទៀតត្រូវហ្វូងមនុស្សខាងលើដុតលើខ្លួន និងត្រូវបុគ្គលផ្សេងៗទៀតវាយទាត់ធាក់រហូតដល់ស្លាប់។

២៥. រដ្ឋអាជ្ញាក្នុងករណីរឿងក្តី *Essen Lynching* បានលើកជាទឡ្ហីករណ៍ថា ចុងចោទម្នាក់ៗត្រូវទទួលខុសត្រូវចំពោះការស្លាប់ទាំងនោះ ដោយនិយាយថា អនុសេនីយ៍ឯកជនជាតិអាល្លឺម៉ង់ជាអ្នក "អុចឈើគូស" នៅពេលគាត់ចេញបញ្ជាជាសាធារណៈ ទាក់ទិននឹងការដឹកជញ្ជូនឈ្លើយសឹក មនុស្សម្នាក់ៗពីហ្វូងមហាជនដែលជាអ្នកគប់សំដៅឈ្លើយសឹក បាន"បោះភ្លើងទៅលើសាំង" ហើយទីបំផុតក៏មាន "ការផ្ទុះ" នៅលើស្ពានតែម្តង។ ជាសរុប រដ្ឋអាជ្ញាបានចោទប្រកាន់ថា៖

> គេមិនអាចផ្តាច់អំពើទាំងនេះចេញពីគ្នាបានទេ ពួកគេទាំងអស់គ្នាជាអ្នកបង្កើតឲ្យមាននូវអ្វីដែលហៅថាការសម្លាប់មនុស្សដោយគ្មានតុលាការការកាត់ទោស។ ចាប់តាំងពីពេលដែលពួកគេបានចាកចេញពីបន្ទាយទាំងនោះ បុរសៗទាំងនេះទទួលរងគ្រោះអន្តរាយ ហើយហ្វូងមហាជនដឹងថាពួកគេទទួលរងគ្រោះអន្តរាយដែរ ហើយមនុស្សទាំងអស់ក្នុងហ្វូងនោះដែលគប់សំដៅឈ្លើយសឹក ត្រូវទទួលខុសត្រូវទាំងផ្នែកសីលធម៌ និងទាំងខាងព្រហ្មទណ្ឌចំពោះការស្លាប់បុរសទាំងបីនាក់នោះ[៣៧]។

២៦. តុលាការហាក់ដូចជាយល់ស្របទៅនឹងទ្រឹស្តីរបស់រដ្ឋអាជ្ញាដែរ ដោយសម្រេចថាអនុសេនីយ៍ឯកពលទោ និងជនស៊ីវិលបីនាក់ទៀតមានពិរុទ្ធភាពពីបទមនុស្សឃាតជាបទឧក្រិដ្ឋសង្គ្រាម[៣៨]។ ទោះបីសាលក្រមមិនបានបញ្ជាក់ច្បាស់ពីទ្រឹស្តីនៃការទទួលខុសត្រូវទៅតាមអ្វីដែលតុលាការសម្រេចឲ្យជនជាប់ចោទម្នាក់ៗត្រូវទទួលខុសត្រូវពីអ្វីក៏ដោយ តែគណៈកម្មការទទួលបន្ទុកឧក្រិដ្ឋសង្គ្រាមរបស់អង្គការសហប្រជាជាតិដែលបានកត់សម្គាល់រឿងក្តីនេះបានថ្លែងថា ជនស៊ីវិលបីនាក់ដែលត្រូវបានផ្តន្ទាទោសនោះ "មានពិរុទ្ធភាព ដោយសារពួកគេម្នាក់ៗបានចូលរួមតាមទម្រង់ណាមួយ ឬ

[៣៦] *រឿងក្តី Essen Lynching* , ទំព័រ ៨៩។

[៣៧] *រឿងក្តី Essen Lynching* , ទំព័រ៨៩។

[៣៨] ជនស៊ីវិលពីរនាក់ត្រូវបានលើកលែងទោស ។ ម្នាក់ "ដោយសារការតែគាត់គប់សំដៅឈ្លើយសឹកនោះមិនបានធ្វើឲ្យមានរបួសធ្ងន់ធ្ងរ ឬបណ្តាលឲ្យពួកអាកាសយានិកទាំងនេះស្លាប់ទេ" ហើយម្នាក់ទៀត "ដោយសារមិនមានបង្ហាញលើសពីវិមតិសង្ស័យថា គាត់ពិតជាបានចូលរួមក្នុងកលយុគនោះទេ" ។ សាលដីកាសាលាឧទ្ធរណ៍លើករណីរឿងក្តីរបស់ *Tadić* , កថាខណ្ឌទី២០៨ ជើងទំព័រលេខ២៥៩។

ទម្រង់ផ្សេងទៀតក្នុងការធ្វើបាប ដែលបណ្តាលឲ្យជនរងគ្រោះត្រូវស្លាប់ ទោះបីមិនមានបញ្ជាក់ច្បាស់ថាជនជាប់ចោទបានបាញ់សម្លាប់ដោយផ្ទាល់ដៃ ឬគប់សំដៅឈ្លើយសឹក ដែលបណ្តាលឲ្យស្លាប់ក៏ដោយ"[៣៩]។ ដូចដែលតុលាការ ICTY បានទទួលស្គាល់ក្នុងរឿងក្តី *Tadić* ដែរ ក្នុងរឿងក្តី *Essen Lynching* នេះ តុលាការទំនងជាអនុវត្តស្មើគ្នានូវការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម III ដែលយ៉ាងហោចណាស់ក៏ពាក់ព័ន្ធនឹងជនជាប់ចោទមួយចំនួនដែរ[៤០]។

២៧. រឿងក្តីទីពីរ ដែលគាំទ្រដល់អត្ថិភាពនៃការទទួលខុសត្រូវ សហកម្មឧក្រិដ្ឋកម្មរួម III នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិគឺ *រឿងក្តី សហរដ្ឋអាមេរិក* ទល់នឹង *Kurt Goebell និងអ្នកដទៃទៀត* ដែលជាទូទៅគេនិយមហៅថា *រឿងក្តីកោះ Borkum*[៤១]។ រឿងក្តីនេះត្រូវបានបើកសវនាការនៅតុលាការយោធាអាមេរិកនៅ Dachau។ អង្គហេតុនៃរឿងក្តី *កោះ Borkum* ស្រដៀងគ្នាជាខ្លាំងទៅនឹងអង្គហេតុនៅក្នុងរឿងក្តី *Essen Lynching* ដែលបានរៀបរាប់ខាងលើគឺថា៖ អាកាសយានិកអាមេរិកមួយក្រុមត្រូវបានចាប់ជាឈ្លើយសឹកនៅក្នុងទឹកដីអាល្លឺម៉ង់ ហើយត្រូវបានគេបណ្តើរកាត់ក្រុងនៃកោះ Borkum ដែលនៅទីនោះ ឈ្លើយសឹកទាំងនោះត្រូវបានគេវាយដំ និងបាញ់សម្លាប់ដោយក្រុមជនស៊ីវិល និងទាហានអាល្លឺម៉ង់ដែលផុតកាតព្វកិច្ច[៤២]។ រឿងនេះបានកើតឡើង ទោះបីមានវត្តមានទាហានអាល្លឺម៉ង់ប្រាំពីរនាក់ ដែលត្រូវបានចាត់តាំងឲ្យនាំឈ្លើយសឹកទាំងនោះ ទៅអង្គភាពកងទ័ពជើងទឹក ដើម្បីដំណើរការការងារបន្តក៏ដោយ[៤៣]។

---

[៣៩] *រឿងក្តី* Essen Lynching , ទំព័រ៩១។

[៤០] សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តីរបស់ *Tadić* , កថាខណ្ឌ២០៩ (ដោយយល់ឃើញថា គេអាចពិចារណាថា "តុលាការបានសន្និដ្ឋានថា ទណ្ឌិត ដែលនាំអាវុធ ឬញុះញង់ដោយមិនច្បាស់លាស់ឲ្យមានការសម្លាប់មនុស្ស អាចត្រូវបានព្យាករណ៍ជាមុនថាអ្នកដទៃទៀត នឹងសម្លាប់អ្នកទោស។ ដូច្នេះ ពួកគេត្រូវបានរកឃើញថា មានពិរុទ្ធនៃពីបទសម្លាប់មនុស្ស")។

[៤១] ទោះបីមិនត្រូវបោះពុម្ពនៅក្នុងរបាយការណ៍របស់គណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាមរបស់សហប្រជាជាតិក៏ដោយ ក៏កំណត់ហេតុពិស្តារនៃរឿងក្តីនេះអាចរកបានជាសាធារណៈតាមរយៈ ការបោះពុម្ពផ្សាយមីក្រូហ្វីលនៃបណ្ណសារជាតិរបស់សហរដ្ឋអាមេរិក (U.S. National Archives Microfilm Publications)។ បណ្ណសាររបស់របស់សហរដ្ឋអាមេរិក ឯកសារបោះពុម្ពលេខM1103 "កំណត់សវនាការលើបទឧក្រិដ្ឋសង្គ្រាមនៃកងទ័ពសហរដ្ឋអាមេរិក" *រឿងក្តី សហរដ្ឋអាមេរិក តទល់នឹង Kurt Goebell និងអ្នកដទៃទៀត* ថ្ងៃទី ៦ ខែ កុម្ភៈ - ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៤៦។ ជាងនេះទៀត របាយការណ៍ពិស្តារនៃសវនាការនេះ (ផ្អែកលើប្រតិចារឹកស្តីពីសវនាការ) ត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៥៦។ *សូមមើល* Maxilimian Koessler "សោកនាដកម្ម និងសវនាការលើរឿងក្តីកោះ Borkum" 47 *Journal of Criminal Law* ទំព័រ១៨៣-១៩៦ (ឆ្នាំ ១៩៥៦)។

[៤២] *សូមមើល* Koessler, ទំព័រ១៨៤-១៨៩។

[៤៣] *សូមមើល* Koessler, ទំព័រ១៨៤-១៨៩ ជាពិសេសទំព័រ១៨៥។

២៨. រដ្ឋអាជ្ញាបានសំអាងរឿងក្ដីរបស់ខ្លួនផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវក្នុងផែនការរួម ដោយបានលើកជាទឡ្ហីករណ៍នៅពេលធ្វើសេចក្ដីថ្លែងបើកការចោទប្រកាន់ថា ជនជាប់ចោទជា“ស្ដីសំរាប់បង្វិលកង់នៃផែនការរួមឲ្យដំណើរការ ដែលទាំងអស់នេះសុទ្ធតែមានសារៈសំខាន់ស្មើៗគ្នា ដែលស្ដីនីមួយៗត្រូវធ្វើការរបស់ខ្លួនទៅតាមផ្នែកដែលគេចាត់តាំង”[៤៤]។ បន្ទាប់ពីបានប្រជុំពិភាក្សាគ្នាជាសម្ងាត់រួចហើយ ចៅក្រមបានចេញសេចក្ដីសម្រេចផ្ដន្ទាទោសផ្ទាល់មាត់ ដោយបានកាត់ក្ដីឲ្យចៅហ្វាយក្រុង និងមន្ត្រីជាច្រើននាក់ឲ្យជាប់ទោសពីបទមនុស្សឃាតផង និងពីបទការវាយប្រហារផង ហើយជនជាប់ចោទដទៃទៀតមានទោសត្រឹមតែពីបទវាយប្រហារតែប៉ុណ្ណោះ។ ទោះបីចៅក្រមមិនបានបញ្ជាក់ពីអង្គច្បាប់ក្ដី តែអង្គហេតុនៃរឿងក្ដី គួបផ្សំជាមួយសេចក្ដីថ្លែងបើកចោទប្រកាន់ទោសរបស់រដ្ឋអាជ្ញាបានបង្ហាញថា តុលាការនេះបានតម្កល់នូវទ្រឹស្ដីផែនការរួម ជាទម្រង់ទូលំទូលាយ។ ជាពិសេស តុលាការនេះបានសម្រេចថា ទោះបីចុងចោទមួយចំនួនមិនបានចូលរួមក្នុងអំពើមនុស្សឃាតក្ដី ឬមិនមានចេតនាចង់ឲ្យមានការប្រព្រឹត្តិនូវបទល្មើសនេះក្ដី តែពួកគេនៅតែទទួលខុសត្រូវដដែល ដោយសារលក្ខណៈដែលអាចប្រមើលមើលថាជាបទឧក្រិដ្ឋ ចំពោះផលវិបាកនៃការប្រព្រឹត្តិរបស់ខ្លួនទៅលើឈ្លើយសឹកទាំងនោះ។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសន្និដ្ឋានថា៖

> គេអាចទាញជាសន្និដ្ឋានពីរឿងក្ដីនេះបានថា ជនជាប់ចោទទាំងអស់ដែលសុទ្ធតែត្រូវបានរកឃើញថាមានពិរុទ្ធភាព ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការខិតខំបន្តអនុវត្តតាមគំរោងផែនការសហកម្មឧក្រិដ្ឋកម្មរួមមួយ ចេតនាគឺជាការវាយប្រហារទៅលើឈ្លើយសឹកទាំងនោះ។ ទោះជាយ៉ាងណាក្ដី ជនជាប់ចោទមួយចំនួនក៏ត្រូវបានរកឃើញថាមានពិរុទ្ធភាព ពីបទមនុស្សឃាតផងដែរ ទោះបីមិនមានភ័ស្ដុតាងថា ពួកគេពិតជាបានសម្លាប់ឈ្លើយសឹកទាំងនោះក៏ដោយ។ ជាការសន្និដ្ឋានមកវិញគឺថា នេះគឺផ្អែកលើមូលដ្ឋានថាជនជាប់ចោទ ទោះបីជាដោយសំអាងលើឋានៈ តួនាទី ឬការប្រព្រឹត្តិរបស់ខ្លួនក៏ដោយ ក៏នៅតែស្ថិតក្នុងជំហរមួយដែលអាចបានព្យាករណ៍ទុកជាមុនហើយថា ការវាយប្រហារដែលធ្វើឡើង ដោយមនុស្សមួយចំនួនដែលបានចូលរួមក្នុងការវាយប្រហារមុខជានឹងបណ្ដាលឲ្យមានការស្លាប់ជនរងគ្រោះជាមិនខាន[៤៥]។

---

[៤៤] សាលដីកាសាលាឧទ្ធរណ៍លើករណីរឿងក្ដីរបស់ *Tadić* កថាខណ្ឌ២១០ (ដកស្រង់ចេញពីដីកាចោទប្រកាន់ក្នុងរឿងក្ដីកោះ Borkum នៅក្នុងការបោះពុម្ពផ្សាយមីក្រូហ្វីលនៃប័ណ្ណសារជាតិ របស់សហរដ្ឋអាមេរិក ទំព័រ១១៨៦)។

[៤៥] សាលដីកាសាលាឧទ្ធរណ៍លើករណីរឿងក្ដីរបស់ *Tadić,* កថាខណ្ឌ២១៣។

២៩. បន្ថែមទៅលើភ័ស្តុតាងនៃសហកម្មឧក្រិដ្ឋកម្មរួម III ជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិ ដែលបានដកស្រង់ខាងលើនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា មានសំអាងហេតុសំខាន់ដែលអាចជឿបានថា ការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម III អាចបង្កើតឋានៈជា "គោលការណ៍ទូទៅនៃច្បាប់" នៅក្នុងច្បាប់អន្តរជាតិបាន[៤៦]។ ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងពីមុនរួចមកហើយគឺថា ក្នុងអំឡុងពេលវេលាដែលពាក់ព័ន្ធមានយុត្តាធិការតុលាការក្នុងស្រុកជាច្រើនបានទទួលស្គាល់ទម្រង់នៃការប្រព្រឹត្តិរួមគ្នាដែលស្រដៀងគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួម III រួមមាន ការផ្សំគំនិតទ្រឹស្តីមនុស្សឃាតជាបទឧក្រិដ្ឋ *ទ្រឹស្តីស្តីពីការរួមសមាគមគ្នានៃអ្នកប្រព្រឹត្តិអំពើអាក្រក់* និងទ្រឹស្តីស្តីពីការរួមគ្នាប្រព្រឹត្តផ្សេងៗទៀត[៤៧]។ ឧទាហរណ៍ ក្រមព្រហ្មទណ្ឌរបស់ប្រទេសហ្វីលីពីនដែលបានធ្វើវិសោធនកម្មឆ្នាំ១៩៣០ ដែលប្រទេសនេះជាសមភាគីក្នុងតំបន់ជាមួយកម្ពុជាដែរនោះ បានទទួលស្គាល់ថា "ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវធ្លាក់ទៅលើ [...] ជនទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋ *(បទមជ្ឈិម)* ទោះបីជាអំពើល្មើសនោះខុសពីចេតនាដែលខ្លួនចង់ធ្វើក៏ដោយ"[៤៨]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងរឿងក្តី *Tadić* បានដកស្រង់ឧទាហរណ៍នានាជាច្រើនដែលបង្ហាញថា ទស្សនទាននេះមានប្រភពមកពីច្បាប់ជាតិនៅតាមបណ្តារដ្ឋនានាជាច្រើន រួមទាំងបណ្តាប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិលផងដែរ ដូចជាប្រទេសបារាំង និងអ៊ីតាលីជាដើម[៤៩]។

---

[៤៦] *សូមមើល* លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ, មាត្រា៣៨(១)(គ)។ កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា១៥(២) (បានបង្ហាញថា វាមិនមែនជាការពំពានដល់គោលការណ៍នីត្យានុកូលភាពក្នុងការចោទប្រកាន់ទោសដល់ជនជាប់ចោទ "ចំពោះបទល្មើសសកម្ម ឬអកម្មណាមួយ ដែលនៅពេលប្រព្រឹត្ត វាបានក្លាយជាបទល្មើសតាមគោលការណ៍ទូទៅនៃច្បាប់ដែលបានទទួលស្គាល់ដោយសហគមន៍ប្រជាជាតិនានា" ទេ)។

[៤៧] *សូមមើល* សេចក្តីសង្ខេបបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌទី១០។

[៤៨] ក្រមព្រហ្មទណ្ឌរបស់ប្រទេសហ្វីលីពីនដែលបានធ្វើវិសោធនកម្ម Act No. 3815, ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៣០, មាត្រា៤។

[៤៩] *សូមមើល* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Tadić* កថាខណ្ឌ២២៤។ *សូមមើលផងដែរ* សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដោយសាស្ត្រាចារ្យ Antonio Cassese និងសមាជិកនានានៃទស្សនាវដ្តីយុត្តិធម៌ ព្រហ្មទណ្ឌអន្តរជាតិ ឯកសារ D99/3/24 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ [ដែលចាប់ពីនេះតទៅហៅថា "សារណារបស់ អ្នកដែលមិនមែនជាភាគីនៃរឿងក្តី JICJ"] កថាខណ្ឌ ៦៣ ដល់ ៦៨ (រៀបរាប់ពីឧទាហរណ៍នានា) ។ គេគួរកត់សម្គាល់ថា តុលាការ ICTY ក្នុងករណីរបស់ *Tadić* បានសន្និដ្ឋានថា ការទទួលស្គាល់ថ្នាក់ជាតិលើគោលបំណងរួមនៃទ្រឹស្តីនេះ មិនអាចត្រូវ បានពឹងផ្អែកទៅលើនោះធ្វើជាការឆ្លុះបញ្ចាំងលើគោលការណ៍អន្តរជាតិមួយបានទេ ព្រោះថា អង្គជំនុំជម្រះបានចាត់ទុកវាជាការ ចាំបាច់ដើម្បីបង្ហាញថា "បើមិនទាំងអស់ទេនោះ ក៏មានប្រទេសភាគច្រើនអនុម័តលើសញ្ញាណដូចគ្នានៃគោលបំណងរួមនេះដែរ" ។ *សូមមើល* សាលដីកាសាលាឧទ្ធរណ៍លើរឿងក្តី *Tadić* កថាខណ្ឌទី ២២៥ ។ នៅក្នុងការសន្និដ្ឋានថា បទដ្ឋាននេះមិនត្រូវបាន គេធ្វើឲ្យត្រូវតាមទេនោះ អង្គជំនុំជម្រះបានកត់សម្គាល់ថា ប្រទេសផ្សេងៗ ដូចជា ប្រទេសអាល្លឺ សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវជាជម្រើសមួយទៀត

៣០. នៅក្នុងសាលដីការបស់ អ.ប.ជ អំពីសហកម្មឧក្រិដ្ឋកម្មរួម អង្គបុរេជំនុំជម្រះបានលើកឡើងពីលទ្ធភាពដែលថា "ប្រព័ន្ធច្បាប់ជាតិមួយចំនួន ដែលអាចត្រូវបានចាត់ទុកថា ជាតំណាងឱ្យប្រព័ន្ធច្បាប់សំខាន់ៗរបស់ពិភពលោក ដែលទទួលស្គាល់ថា បទដ្ឋាននៃ*ចេតនាឧក្រិដ្ឋ* ដែលទាបជាងចេតនាផ្ទាល់ អាចអនុវត្តបានទាក់ទិននឹងបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តឡើង ខាងក្រៅគោលបំណងឧក្រិដ្ឋរួម និងចាត់ទុកថាជាការប្រព្រឹត្តិ"[៥០]។ ទោះបីជាយ៉ាងណាក៏ដោយ ទីបំផុតអង្គបុរេជំនុំជម្រះបានបដិសេធមិនធ្វើការ សម្រេចលើបញ្ហានេះដោយហេតុថា ទោះបីជាទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួមគឺអាចផ្តន្ទាទោសបានដោយផ្អែកលើគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌក៏ដោយ ក៏ទម្រង់ទីបីនេះមិនយកមកអាចអនុវត្តនៅ អ.វ.ត.ក បានដែរ ពីព្រោះវាមិនអាចឱ្យជនជាប់ចោទធ្វើការព្យាករណ៍ជាមុនបាន[៥១]។

៣១. ដូចដែលបានពិភាក្សាខាងក្រោមនៅក្នុងផ្នែក គ សហព្រះរាជអាជ្ញាជឿជាក់ថា អង្គបុរេជំនុំជម្រះមានការភ័ន្តច្រឡំអង្គច្បាប់ នៅក្នុងការវាយតម្លៃលើបញ្ហាថាតើការអនុវត្តទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III អាចព្យាករណ៍ជាមុនបានឬយ៉ាងណា ហេតុនេះមានការភ័ន្តច្រឡំនៅក្នុងការសម្រេចថាអង្គបុរេជំនុំជម្រះមិនត្រូវការកំណត់លើបញ្ហាថាតើ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ទូទៅនៃច្បាប់នៅក្នុងពេលវេលាដែលពាក់ព័ន្ធឬយ៉ាងណាឡើយ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មិនបង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធទេនោះ វាជាការត្រឹមត្រូវ និងជាការណែនាំដល់អង្គជំនុំជម្រះសាលាដំបូង ឱ្យធ្វើការស្នើសុំសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីពីស្ថាប័នសិក្សា ឬស្រាវជ្រាវដែលមានគុណវឌ្ឍន៍

---

ម៉ង់ដ៍ និង ប្រទេសហុល្លង់ដ៍ ជាដើម មិនបានដាក់ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌនេះ ឱ្យជនជាប់ចោទទទួលខុសត្រូវរ៉ាប់រងលើឧក្រិដ្ឋកម្មនានា ដែលត្រូវបានធ្វើឡើងដោយអ្នកចូលរួមប្រព្រឹត្តផ្សេងៗទៀត ដែលមិនត្រូវបានគ្រោងទុកជាមុននៅក្នុងផែនការរួមដំបូង នោះទេ ។ *ដដែលដូចមុន,* កថាខណ្ឌទី ២២៤ ។ ទោះជាយ៉ាងនេះក៏ដោយ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ស្នើឡើងថា "ការទួលយកជា សាកលនូវគោលការណ៍ដ៏ជាក់លាក់មួយដោយបណ្តាប្រជាជាតិនីមួយៗនៅក្នុងប្រព័ន្ធច្បាប់ដ៏ធំៗទាំងនោះ គឺ[មិន]ចាំបាច់ឡើយ នៅមុនពេលដែលចន្លោះប្រហោងអាចត្រូវបានបំពេញនោះ ។ វាជាការគ្រប់គ្រាន់ហើយដែលថា "មានប្រជាជាតិដ៏ច្រើនលើស លប់នៅក្នុងគ្រួសារច្បាប់ដ៏ធំនីមួយៗ" បានទទួលស្គាល់នូវគោលការណ៍បែបដូច្នោះរួចហើយ" ។ *សូមមើល, ជាឧទា. ករណី របស់ រដ្ឋអាជ្ញា ទល់នឹង* Erdemović, សំណុំរឿងលេខ IT-96-22-A, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍, ថ្ងៃទី៧ តុលា ១៩៩៧, ការយល់ឃើញ ដោយឡែករបស់ចៅក្រម Stephen, កថាខណ្ឌទី ២៥ ។

[៥០] សាលដីការបស់ អ.ប.ជ អំពី JCE, កថាខណ្ឌទី ៨៧។ *សូមមើល* ទូទៅ ដូចខាងលើ កថាខណ្ឌទី ៨៤ ដល់ ៨៧។

[៥១] សាលដីការបស់ អ.ប.ជ អំពី JCE, កថាខណ្ឌទី ៨៧។

អំពីបញ្ហាថាតើការទទួលខុសត្រូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នៅតែអាចអនុវត្តបាននៅ អ.វ.ត.ក ដោយផ្អែកលើស្ថានភាពនៃទម្រង់នៃជា "គោលការណ៍ទូទៅនៃច្បាប់ដែលត្រូវបានទទួលស្គាល់ដោយប្រទេសជាតិដែលមានអារ្យធម៌" នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ ឬយ៉ាងណា។ សហព្រះរាជអាជ្ញាលើកឡើងថា ការវិភាគដ៏ល្អិតល្អន់ដែល*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែលមានគុណវឌ្ឍន៍អាចផ្តល់ឲ្យបាននឹងមានប្រយោជន៍នៅក្នុងដំណាក់កាលនេះ បន្ទាប់ពីពិចារណាអំពីភាពទូលំទូលាយ និងភាពស្មុគស្មាញនៃការស្ទង់មតិប្រៀបធៀបដែលចាំបាច់ និងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី នៅពេលដែលភាគីនានាមានការពាក់ព័ន្ធខ្លាំងនៅក្នុងការរៀបចំសវនាការ។ ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញានឹងស្នើសុំការអនុញ្ញាតដាក់សារណាបន្ថែមស្តីពី បញ្ហានេះ។

## គ. ការយកមកអនុវត្តនូវទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III គឺអាចឲ្យជនជាប់ចោទប្រមើលមើលដឹងជាមុនបាន និងអាចរកបាន

៣២. ដូចដែលបានពិភាក្សាខាងលើ ដើម្បីអនុវត្តនូវទម្រង់ជាពិសេសណាមួយនៃការទទួលខុសត្រូវត្រូវតែបានបង្ហាញឲ្យបានគ្រប់គ្រាន់ឲ្យតុលាការឃើញថា ការអនុវត្តនេះមានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាព គឺបានន័យថា ទម្រង់នៃការទទួលខុសត្រូវគ្រប់គ្រាន់មានលក្ខណៈគ្រប់គ្រាន់អាចឲ្យព្យាករណ៍ទុកជាមុនបាន និងថាច្បាប់ដែលចែងអំពីទម្រង់នេះមានគ្រប់គ្រាន់ដែលអាចឲ្យងាយរកបាន នៅក្នុងពេលវេលាដែលពាក់ព័ន្ធ[៥២]។ លក្ខខណ្ឌតម្រូវទាំងពីរយ៉ាងនេះ ត្រូវបានបំពេញគ្រប់សព្វទាក់ទងហើយនឹងការយកទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មកអនុវត្តនៅ អ.វ.ត.ក។

៣៣. ចំពោះមែកធាងនៃការអាចឲ្យព្យាករណ៍ទុកជាមុនបាន នៃការសាកល្បងអំពីគោលការណ៍នីត្យានុកូលភាព សហព្រះរាជអាជ្ញាជូនជាសេចក្តីសន្និដ្ឋានថា យុត្តិសាស្ត្រអន្តរជាតិដែលលើកមកសំអាងខាងលើនេះ បានធ្វើការជូនដំណឹងដល់ជនជាប់ចោទថា ការចូលរួមរបស់ពួកគេនៅក្នុងផែនការរួមអាចនឹងបណ្តាលឲ្យមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ មិនចំពោះតែអំពើទាំងឡាយដែលត្រូវបានរួមបញ្ចូលដោយចេតនានៅក្នុងផែនការរួមនេះទេ ថែមទាំងចំពោះអំពើឧក្រិដ្ឋ ទាំងឡាយដែលកើតចេញមក ក្នុងលក្ខណៈជាផលវិបាកជាធម្មជាតិ និងអាចដឹងឲ្យព្យាករណ៍ទុកជាមុនបាននៃការអនុវត្តផែនការនេះផងដែរ។ ការដែលអាចឲ្យព្យាករណ៍ទុកជាមុនបាន អំពីការ

[៥២] សាលដីកាលើរឿងក្តី *Milutinović* , កថាខណ្ឌទី ៣៧។

អនុវត្តទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ក៏ត្រូវបានគាំទ្រដោយអង្គហេតុដែលថា មានយុត្តិសាស្ត្រជាតិជាច្រើននៅពេលនោះ បានទទួលស្គាល់ទម្រង់នៃការរួមគ្នាប្រព្រឹត្តដែលស្រដៀងគ្នានឹងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នេះ[៥៣]។ ឧទាហរណ៍ ច្បាប់បារាំងដែលបានជះឥទ្ធិពលនៅក្នុងការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់របស់កម្ពុជា បានចែងអំពីការដាក់កម្រិតការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើទាំងឡាយ ដែលប្រព្រឹត្តឡើងដោយជនសមគំនិតដែលធ្វើហួសពីផែនការឧក្រិដ្ឋ នៅពេលដែលការប្រព្រឹត្តិមានទំនាក់ទំនងខ្លះទៅនឹងបទឧក្រិដ្ឋដែលបានគ្រោងទុក[៥៤]។

៣៤. ដូចដែលបានកត់សម្គាល់ខាងលើ អង្គបុរេជំនុំជម្រះបានសម្រេចថា អង្គបុរេជំនុំជម្រះមិនចាំបាច់ធ្វើការសម្រេចឡើយថាតើ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ត្រូវបានទទួលស្គាល់ថាជាគោលការណ៍ទូទៅនៃច្បាប់ ពីព្រោះអង្គបុរេជំនុំជម្រះមិនពេញចិត្តឡើយ ថាទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួមអាចព្យាករណ៍ជាមុនបានចំពោះជនជាប់ចោទ ក្នុងឆ្នាំ១៩៧៥ ដល់១៩៧៩[៥៥]។ នៅក្នុងការពន្យល់អំពីមូលហេតុអ្វីបានជាអង្គបុរេជំនុំជម្រះ "មិនពេញចិត្ត" អង្គបុរេជំនុំជម្រះបានលើកឡើងថា អង្គបុរេជំនុំជម្រះ "មិនទាន់អាចកំណត់បាននៅឡើយទេ នៅក្នុងច្បាប់កម្ពុជា ដែលអាចអនុវត្តបាននៅពេលវេលាដែលពាក់ព័ន្ធនូវបទបញ្ញត្តិណាមួយដែលអាចផ្តល់ជាការជូនដំណឹងដល់ជនត្រូវចោទថា ទម្រង់ទូលំទូលាយនៃការទទួលខុសត្រូវ ក៏អាចផ្តន្ទាទោសផងដែរ"[៥៦]។

៣៥. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា គោលការណ៍នីត្យានុកូលភាពមិនកំណត់សន្និដ្ឋានថា គោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នឹងគ្រាន់តែអាចឱ្យជនជាប់ចោទព្យាករណ៍ជាមុនបានប៉ុណ្ណោះទេ ប៉ុន្តែគោលការណ៍នេះថែមទាំងត្រូវបានចងក្រងឱ្យទៅជាក្រមនៅក្នុងច្បាប់ជាតិទៀតផងទេ។ ខណៈដែលច្បាប់ជាតិចែងថា អំពើណាមួយត្រូវបានចាត់ទុកថាជាអំពើឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ជានិច្ចកាលវាមិនសុទ្ធតែដូច្នេះទាំងអស់នោះទេ ជាពិសេសពាក់ព័ន្ធទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៥៧]។ ក្នុងករណីណាក៏ដោយ

---

[៥៣] សូមមើលខាងក្រោម, កថាខណ្ឌទី ២៩។

[៥៤] *សូមមើល* សាលដីកាសាលាឧទ្ធរណ៍លើករណីរឿងក្តីរបស់ *Tadić* កថាខណ្ឌ២២៤ កំណត់សម្គាល់ ២៨៥ (ដែលបានដកស្រង់សាលដីកាតុលាការកំពូលរបស់តុលាការបារាំងឆ្នាំ ១៩៤៧ ដែលបានលើកឡើងថា បទសមគំនិត "devait prévoir toutes les qualifications dont le fait était susceptible, toutes les circonstances dont il pouvait être accompagné" គឺថា "ត្រូវរំពឹងទុកថានឹងត្រូវបានចោទប្រកាន់ លើគ្រប់បទចោទទាំងអស់តាមដែលច្បាប់អនុញ្ញាតឱ្យ និងរាល់ផលវិបាកទាំងអស់ដែលអាចកើតចេញមកពីបទឧក្រិដ្ឋនោះ" (បកប្រែក្រៅផ្លូវ ការ)។

[៥៥] សាលដីការបស់ អ.ប.ជ អំពី JCE , កថាខណ្ឌទី ៨៧។

[៥៦] សាលដីការបស់ អ.ប.ជ អំពី JCE, កថាខណ្ឌទី ៨៧។

[៥៧] សាលដីកាលើរឿងក្តី *Milutinović,* កថាខណ្ឌទី ៤១។

សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ("ក្រមព្រហ្មទណ្ឌ") ដោយការប្រើពាក្យថា "បទសមគំនិត" ថាជាទម្រង់នៃការទទួលខុសត្រូវមួយដែលជាទូទៅគាំទ្រដល់ទស្សនទានដែលជាដើមចមនៃសហកម្មឧក្រិដ្ឋកម្មរួម III ជាទូទៅគាំទ្រទស្សនាទានដែលបានគូសបញ្ជាក់ពីទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III[៥៨]។ ចំណុចនេះគូសបញ្ជាក់ថែមទៀត អំពីភាពអាចឱ្យជនជាប់ចោទព្យាករណ៍ទុកជាមុនបាន និងការដែលអាចឱ្យរកបានដោយងាយនូវច្បាប់ដែលចែងពីទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នេះ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

៣៦. ការសន្និដ្ឋានថា ទម្រង់នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម III អាចឱ្យព្យាករណ៍ជាមុនបាន ក៏ត្រូវបានគាំទ្រតាមរយៈលក្ខណៈនៃបទឧក្រិដ្ឋនានាដែលធ្វើឡើងដោយខ្មែរក្រហម នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធផងដែរ។ វាមិនអាចជឿបានឡើយថា អ្នកដែលប្រកបដោយវិចារណញ្ញាណនឹងមិនបានឱ្យតម្លៃទេថា ការចូលរួមរបស់ពួកគេនៅក្នុងផែនការរួម ដែលជាលទ្ធផលចេញមកពីការអាចព្យាករណ៍ជាមុនបានដែលក្នុងនោះរួមបញ្ចូលទាំងអំពើឃោរឃៅជាទ្រង់ទ្រាយធំ បានរំលោភលើបទបញ្ញត្តិនៃច្បាប់ជាសកល និងលើភាពសមរម្យ ដូចជាការអនុញ្ញាតឱ្យធ្វើទៅជាឧក្រិដ្ឋបនីយកម្ម[៥៩]។

៣៧. ពាក់ព័ន្ធទៅនឹងការអាចរកបាននៃមែកធាងអំពីគោលការណ៍នីត្យានុកូលភាព វិធីសាស្ត្រទូទៅរបស់តុលាការអន្តរជាតិផ្សេងៗទៀត គឺការសន្មតថា លក្ខខណ្ឌតម្រូវឱ្យមានភាពអាចឱ្យព្យាករណ៍ទុកជាមុនបាន និងអាចរកបាននោះ អំពើដែលបានប្រព្រឹត្តហើយ អាចត្រូវបានផ្តន្ទាទោសនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[៦០]។ ដូចដែលបានពិភាក្សាគ្នាខាងលើ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III បានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ ហេតុដូច្នេះហើយ គួរតែត្រូវបានសន្មតថា ជនជាប់ចោទអាចរកបាន។ ជនជាប់ចោទមិនចាំបាច់ត្រូវតែដឹងពិតប្រាកដអំពីការ

---

[៥៨] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មាត្រា ១៤៥។ *សូមមើលផងដែរ* "សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី JICJ" កថាខណ្ឌ ៧៤ ដល់ ៨០។

[៥៩] សាលដីកាលើរឿងក្តីរបស់ *Milutinović,* កថាខណ្ឌទី ៤២ (ដែលបានលើកឡើងថា "ទោះបីជាចរិតអសីលធម៌ និងគួរឱ្យខ្លាចនៃអំពើមួយមិនមែនជាកត្តាគ្រប់គ្រាន់ក្នុងការអះអាងពីការធ្វើឱ្យទៅជាបទឧក្រិដ្ឋក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ជាការពិត វាអាចដើរតួនាទីពាក់ព័ន្ធនឹងបញ្ហានេះ ក្នុងវិសាលភាពដែលវាអាចជំទាស់នឹងការទាមទាររបស់មេធាវីការពារក្តីថា វាមិនបានដឹង អំពីលក្ខណៈព្រហ្មទណ្ឌ នៃអំពើទាំងឡាយនោះទេ")។

[៦០] សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីសម្រាប់អង្គបុរេជំនុំជម្រះស្តីពីសហកម្មឧក្រិដ្ឋកម្មរួម របស់មជ្ឈមណ្ឌល ដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់ របស់សកលវិទ្យាល័យ MCGill , សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៨-០៧-២០០៧-អវតក/កសចស (អបជ ០២), ឯកសារ D99/3/25 ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ (ដែលចាប់ពីនេះតទៅហៅថា "សារណា របស់ McGill"), កថាខណ្ឌ ១៣។ ករណីរឿងក្តី របស់ *រដ្ឋអាជ្ញា* ទល់នឹង *Martic* តុលាការ ICTY, IT-95-11-A, សាលដីកាលើបណ្តឹង ឧទ្ធរណ៍, យោបល់ដាច់ដោយឡែកពីគ្នារបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គលរបស់ Milan Martic, ចុះថ្ងៃ ទី ៨ ខែ តុលា ឆ្នាំ ២០០៨។

ទទួលខុសត្រូវ ដែលអាចមានអនុលោមតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III នោះទេ[៦១]។ ក្នុងករណីណាក៏ដោយ ភ័ស្តុតាងដែលចាំបាច់ដើម្បីធ្វើការសន្និដ្ឋានថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ដែលមានជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ពិតជាមានស្រាប់ និងដែលអាចឲ្យរកបានដោយងាយ នៅក្នុងអម្លុងពេលវេលាដែលពាក់ព័ន្ធ។ រឿងក្តីពាក់ព័ន្ធនឹងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ភាគច្រើន ត្រូវបានបោះពុម្ពផ្សាយក្នុងទម្រង់ជាសង្ខេប ដែលបានធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវរបាយការណ៍ជាផ្លូវការ របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិឆ្នាំ១៩៤៩។ ស្រដៀងគ្នានេះដែរ ធម្មនុញ្ញតុលាការអន្តរជាតិទីក្រុងនូរ៉ាំប៊ឺហ្គ និងសេចក្តីសម្រេចនានាដែលកើតចេញមកពីរបាយការណ៍នេះ ត្រូវបានបោះពុម្ពផ្សាយ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងយ៉ាងល្អ នៅមុនឆ្នាំ១៩៧៥។

## ឃ. ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មានភាពស៊ីសង្វាក់គ្នាជាមួយកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

៣៨. សហព្រះរាជអាជ្ញាសូមជូនជាសេចក្តីសន្និដ្ឋានថា ទ្រឹស្តីនៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III មានភាពស៊ីសង្វាក់គ្នាជាមួយនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងលិខិតបករណ៍អន្តរជាតិនានា និងយុត្តិសាស្ត្រនៅក្រោយពេលសង្គ្រាមលោកលើកទី២។ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III ការពារសង្គមប្រឆាំងទល់នឹងជនទាំងឡាយណាដែល (១) រួមគ្នាចូលរួមចំណែកនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។ និង (២) ដឹងទុកជាមុន ឬគួរតែដឹងជាមុនអំពីឧក្រិដ្ឋកម្មនៅក្នុងពេលអនាគត ប៉ុន្តែនៅតែបន្តចូលរួមចំណែកក្នុងសហកម្មឧក្រិដ្ឋកម្មរួម និងខកខានមិនបានទប់ស្កាត់ឬបញ្ឈប់អំពើឧក្រិដ្ឋបន្ថែមក្រៅផែនការរួម ឬឲ្យឈប់ធ្វើសហកម្មឧក្រិដ្ឋកម្មដើម្បីចៀស វាងកុំឲ្យក្លាយទៅជាអ្នកចូលរួមនៅក្នុងឧក្រិដ្ឋកម្មបន្ថែមទៀត។ សហគមន៍ពិភពលោកមានការចាប់អារម្មណ៍យកចិត្តទុកដាក់ខ្លាំង ក្នុងការធ្វើឲ្យមានការខ្លាចញញើតលែងហ៊ានប្រព្រឹត្តនូវអំពើដ៏ព្រៃផ្សៃ និងការធ្វេសប្រហែលប្រភេទនេះ ជាពិសេស ពីព្រោះបានកត់សំគាល់ដោយលោក Steyn ព្រឹទ្ធសមាជិកនៃព្រឹទ្ធសភា ចក្រភពអង់គ្លេស និងវែលហ្ស៍ ថា "បទពិសោធន៍នានាបានបង្ហាញថា សហកម្មឧក្រិដ្ឋកម្មរួមគ្រាន់តែជាការត្រៀមលក្ខណៈជាស្រេច ដើម្បីសំដៅទៅលើការប្រព្រឹត្តិបទល្មើសដែលកាន់តែធំជាងនេះទៀតតែប៉ុណ្ណោះ"[៦២]។

---

[៦១] *ការមិនដឹងច្បាប់មិនអាចធ្វើជាការដោះសារបានទេ (ignorantia juris non excusat)*។

[៦២] ករណីរឿងក្តីរបស់ *Regina* ទល់នឹង *Powell* និងគូកន និងករណីរឿងក្តីរបស់ *Regina* ទល់នឹង ប្រទេសអង់គ្លេស, ព្រឹទ្ធសភានៃចក្រភពអង់គ្លេស, ១៩៩៩ , 1 A.C. 1.ទំព័រ១៤។

៣៩. ទ្រឹស្តីនៃទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III គឺជាយន្តការសមស្រប និងចាំបាច់មួយសម្រាប់លើកឡើងពីការគំរាមកំហែងពិសេសតែមួយគត់ដែលបង្កដោយឧក្រិដ្ឋភាព ដែលគេបានរៀបចំទុក និងការតតាំងពិសេស តែមួយគត់នៃការចោទប្រកាន់ចារីទាំងនេះ។ នៅក្នុងបរិបទនេះ មានការពាក់ព័ន្ធដែលត្រូវកត់សម្គាល់ថា អត្ថន័យព្រហ្មទណ្ឌនៃការសម្រេចបាននូវគោលដៅរួមនៃសហកម្មឧក្រិដ្ឋកម្មរួម មិននៅនឹងថ្កល់ និងអាចវិវដ្តតាមពេលវេលា។ ដូចដែលតុលាការពិសេសសម្រាប់ប្រទេសលីបង់បានសង្កេតឃើញ "ដើមឡើយ នៅពេលដែលអ្នកចូលរួមនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមអាចមានការយល់ស្របចំពោះឧក្រិដ្ឋម្មតែមួយចំនួនតូច ឧក្រិដ្ឋកម្ម "ស្នូល" តែប៉ុណ្ណោះ អ្វីដែលអាចដឹងជាមុនបាន ថាជាបទឧក្រិដ្ឋនៅដំណាក់កាលដំបូងនៃសហកម្មឧក្រិដ្ឋកម្មរួម អាចធ្វើឱ្យទទួលយល់ព្រមទាំងស្រុងបានចំពោះគោលដៅឧក្រិដ្ឋរបស់សមាជិកសហកម្មឧក្រិដ្ឋកម្មរួម ដែលមានចំនួនកើនឡើង"[៦៣]។ ដូចនេះ ភាពខុសគ្នារវាងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម I ដែលតម្រូវឱ្យមានចេតនាផ្ទាល់ និងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III "ដែលតាមផ្នែកទ្រឹស្តីជាសំខាន់ គឺមិនអាចក្លាយទៅជាស្នូលដូចនេះបានទេ នៅពេលដែលទាក់ទងទៅនឹងភ័ស្តុតាងជាក់ស្តែង ហើយដែលអនុញ្ញាតឱ្យទាញចេញជាសេចក្តីសន្និដ្ឋានបានថា៖ ជាញឹកញាប់ នៅពេលអ្នកចូលរួមនៅក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម បានដឹងជាមុនអំពីឧក្រិដ្ឋកម្មបន្ថែម ដែលកាលពីដើមឡើយ គាត់មិនបានចូលរួមទេ ហើយទោះបីជាគាត់ឯកភាព ឬមិនឯកភាពក៏ដោយ នៅតែបន្តផ្តល់នូវការចូលរួមចំណែកដ៏សំខាន់ទៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ការទាញជាសេចក្តីសន្និដ្ឋានដ៏សមហេតុផលតែមួយគត់អាចថាគាត់បានទទួលយល់ព្រមចំពោះឧក្រិដ្ឋបន្ថែមទៀតនោះ ហេតុដូចនេះបានធ្វើឱ្យការទទួលខុសត្រូវរបស់គាត់វិលត្រឡប់ចូលមកនៅក្នុងទម្រង់ជាសហកម្មឧក្រិដ្ឋកម្មរួម I វិញ" [៦៤]។

៤០. លើសពីនេះទៀត ទោះបីជាគេបានលើកឡើងថា ការអនុវត្តទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III បានពង្រីកវិសាលភាពនៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដោយមិនសមហេតុផល ឬជាលទ្ធផលនៃការប្រព្រឹត្តិបង្កើតបានជាឧក្រិដ្ឋបនីយកម្ម ដែលក្នុងនោះរួមទាំងពិរុទ្ធភាព ដែលមានលក្ខណៈតូចតាចផង នេះគឺមិនមែនករណីដូច្នេះទេ។ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា នៅពេលចារីដែលស្ថិតក្រោមទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម III អាចមិនមានពិរុទ្ធភាពដូចជា ជនល្មើសសំខាន់នោះ ការប្រព្រឹត្តិរបស់គាត់នៅតែមានលក្ខណៈធ្ងន់ធ្ងរដដែល ហើយដែលសក្តិសមនឹងទទួល

---

[៦៣] សេចក្តីសម្រេចបន្ទាន់បង្គំរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់, កថាខណ្ឌទី ២៤៦។

[៦៤] សេចក្តីសម្រេចបន្ទាន់បង្គំរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់, កថាខណ្ឌទី ២៤៦។

ការផ្តន្ទាទោស ហើយភាពខុសគ្នាណាមួយស្តីពីកម្រិតនៃពិរុទ្ធភាព គឺគួរតែត្រូវបានយកចិត្តទុកដាក់ គិតគូរពិចារណាឲ្យបានត្រឹមត្រូវជាងនេះ នៅក្នុងដំណាក់កាលធ្វើការផ្តន្ទាទោស[៦៥]។

## V. សេចក្តីសន្និដ្ឋាន

៤១. តាមរយៈមូលហេតុនានាដូចដែលបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើ៖ (ក) សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III គឺជាទម្រង់នៃការទទួលខុសត្រូវដែលមានសុពលភាព នៅ អ.វ.ត.ក (ខ) សុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាថ្មីឡើងវិញ តាមករណីសមស្រប នៅក្នុងពេលចេញសាលក្រមថាជាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត អនុលោមតាមទម្រង់ដែលពង្រីកបន្ថែមនៃសហកម្មឧក្រិដ្ឋកម្មរួម គឺបានន័យថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III (គ) សុំឲ្យអង្គជំនុំជម្រះ សាលាដំបូងសម្រេចលើបញ្ហាថាតើ ទម្រង់សហកម្មឧក្រិដ្ឋកម្មរួម III អាចត្រូវបានអនុវត្តនៅ អ.វ.ត.ក មុនពេលចាប់ផ្តើមសវនាការបានដែរ ឬទេ ឬជាជម្រើសម្យ៉ាងទៀត សុំឲ្យធ្វើការជូនដំណឹងថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកបញ្ហានេះ ដើម្បីទៅធ្វើការពិចារណាតាមទស្សនទាននេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[៦៥] *សូមមើល* សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្គំរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់, កថាខណ្ឌ ២៤៥ (ដែលបានលើកឡើងថា (១) នៅពេលដែលជនល្មើសបន្ទាប់បន្សំគ្មានចេតនា (ចេតនាទុច្ចរិត dolus) ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមិនបានព្រមព្រៀងគ្នា ... បទល្មើសក្រៅបន្ថែមនោះអាចធ្វើទៅបានដោយសារការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្ម [ដែលត្រូវរួមបញ្ចូលនូវការរួមចំណែកសំខាន់ដើម្បីសម្រេចឲ្យបាននៃផែនការរួមរបស់សហកម្មឧក្រិដ្ឋកម្មរួម] និងដោយសារការខកខានរបស់គាត់ក្នុងការឈប់ ឬបញ្ឈប់បទល្មើសក្រៅបន្ថែមទៀត នៅពេលដែលគាត់អាចដឹងជាមុនអំពីបទល្មើសក្រៅបន្ថែមនោះ" និង (២) កម្រិតទាបជាងនៃពិរុទ្ធភាព និងភាពគួរស្តីបន្ទោសរបស់ជនល្មើសបន្ទាប់បន្សំដែលត្រូវយកចិត្តទុកដាក់ពិចារណានៅក្នុងដំណាក់កាលនៃការផ្តន្ទាទោស)។